បណ្ណាល័យ
គ.ជ.អ.ប

រាជរដ្ឋាភិបាលកម្ពុជា
គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

# ប្លង់មេរៀនសំរាប់គ្រូបណ្តុះបណ្តាល
# ស្តីពី
# ការរៀបចំកម្មវិធីវិនិយោគ៣ឆ្នាំរំកិល
# របស់ឃុំ សង្កាត់

354.968 PLA-COM
Training

library.ncdd.gov.kh
002995

ខែកក្កដា ឆ្នាំ២០០៣

# មាតិកាអត្ថបទ


ក្របខណ្ឌពេលវេលាសំរាប់ការរៀបចំកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ឃុំ សង្កាត់

កម្មវិធីបណ្តុះបណ្តាល

ប្លង់មេរៀនជំហានទី១ :

ក). ការកែសំរួល និងវិភាគផែនទីឃុំ សង្កាត់ ១

ខ). ការវិភាគតាមឯកសារពត៌មានស្ថានភាពឃុំ សង្កាត់ ៧

គ). ការកំណត់បញ្ហា តំរូវការ និងដំណោះស្រាយឃុំ សង្កាត់ តាមរយៈបទពិសោធន៍ និងឧបករណ៍វិភាគផ្សេងៗទៀត ៩

ប្លង់មេរៀនជំហានទី២ : ការប្រជុំពិភាក្សាជាមួយប្រជាពលរដ្ឋក្នុងភូមិ ១២

ប្លង់មេរៀនជំហានទី៣ : ការចាត់អាទិភាពដំណោះស្រាយនៅថ្នាក់ឃុំ សង្កាត់ ១៦

ប្លង់មេរៀនជំហានទី៤ : ការកំណត់ទិសដៅ និងយុទ្ធសាស្ត្រវិនិយោគ ២៨

ប្លង់មេរៀនជំហានទី៥ : ការកំណត់គំរោងដែលត្រូវវិនិយោគ ៣៣

ប្លង់មេរៀនជំហានទី៦ : ការព្យាករណ៍ទុនវិនិយោគ ៤០

ប្លង់មេរៀនជំហានទី៧ : ការរៀបចំតារាងគំរោងវិនិយោគជាអាទិភាព ៤២

ប្លង់មេរៀនជំហានទី៨ : សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ ៤៤

ប្លង់មេរៀនជំហានទី៩ : ការសំរេចចុងក្រោយលើគំរោងនានាក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ ៤៨

ប្លង់មេរៀនជំហានទី១០ : ការចងក្រងសៀវភៅកម្មវិធីវិនិយោគឃុំ សង្កាត់ ៥៩

ប្លង់មេរៀនជំហានទី១១ : ការរៀបចំអនុម័តឯកសារកម្មវិធីវិនិយោគឃុំ សង្កាត់ ៦១

# គ្រោងពេលវេលា

## សម្រាប់ការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់

កម្មវិធីវិនិយោគបីឆ្នាំរំកិល គឺជាកម្មវិធីផ្ដោតការយកចិត្តទុកដាក់រយៈពេលខ្លីមួយ ។ រយៈពេលអនុវត្តគំរោងខុសៗគ្នា អាស្រ័យទៅលើគំរោងទាំងនោះ ក៏ប៉ុន្តែ វដ្ដនៃការកសាងផែនការ សម្រាប់កែសម្រួលកម្មវិធីវិនិយោគ គឺតិច ឬច្រើនមានលក្ខណៈទូទាំងប្រទេស ដូចខាងក្រោម ៖

- សប្ដាហ៍ទី២ ខែសីហា ៖ ការបណ្ដុះបណ្ដាលគ្រូឧទ្ទេសថ្នាក់ជាតិ ។
- សប្ដាហ៍ទី៣ ខែសីហា ៖ ការត្រៀមរៀបចំសំរាប់ការបណ្ដុះបណ្ដាលអ្នកសំរបសំរួលខេត្ត ក្រុង និងស្រុក ខណ្ឌ នៅតាមបណ្ដាខេត្ត ក្រុង ។
- សប្ដាហ៍ទី៤ ខែសីហា ៖ ការបណ្ដុះបណ្ដាលអ្នកសំរបសំរួល នៅតាមបណ្ដាខេត្ត ក្រុង ។
- ខែកញ្ញា ៖ អនុវត្តជំហានទី១ ទី២ ទី៣ និងទី៤ ។ អ្នកសំរបសំរួលស្រុក ខណ្ឌ ម្នាក់ទទួលខុសត្រូវបីឃុំ សង្កាត់ ។

| សប្ដាហ៍ទី | ជំហានទី១ | ជំហានទី២ | ជំហានទី៣ និងទី៤ |
|---|---|---|---|
| ១ | ឃុំ សង្កាត់ទី១ | | |
| ២ | ឃុំ សង្កាត់ទី២ | ឃុំ សង្កាត់ទី១ | |
| ៣ | ឃុំ សង្កាត់ទី៣ | ឃុំ សង្កាត់ទី២ | |
| ៤ | | ឃុំ សង្កាត់ទី៣ | ឃុំ សង្កាត់ទី១ ទី២ និងទី៣ |

- សប្ដាហ៍ទី១ និងទី២ ខែតុលា ៖ ជំហានទី៥ ជំហានទី៦ និងជំហានទី៧ ។
- ពាក់កណ្ដាលខែតុលា ដល់ពាក់កណ្ដាលខែវិច្ឆិកា ៖ ជំហានទី៨ "សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ" ។ (ចំពោះខេត្ត ក្រុងមួយចំនួនដែលមានចំនួនឃុំ សង្កាត់តិច អាចចំណាយពេលវេលាតិចជាងនេះ) ។
- ចាប់ពីពាក់កណ្ដាលខែតុលា ៖ ជំហានទី៩ ជំហានទី១០ និងជំហានទី១១ (រួមទាំងការសិក្សាលទ្ធភាពគំរោង) ។

# កម្មវិធីបណ្តុះបណ្តាល

| ពេលវេលា | កម្មវិធីបណ្តុះបណ្តាល |
|---|---|
| ថ្ងៃទី១ | |
| ០៨:០០-០៨:៣០ | ពិធីបើកវគ្គបណ្តុះបណ្តាល |
| ០៨:៣០-១០:១៥ | ជំហានទី១ : ក). ការកែសម្រួល និងវិភាគផែនទីឃុំ សង្កាត់ |
| ១០:១៥-១០:៣០ | សម្រាក |
| ១០:៣០-១២:០០ | ជំហានទី១ : ខ). ការវិភាគតាមឯកសារពត៌មានស្ថានភាពឃុំ សង្កាត់ |
| ១២:០០-១៤:០០ | សម្រាកពិសារបាយថ្ងៃត្រង់ |
| ១៤:០០-១៥:០០ | ជំហានទី១ : ខ). ការវិភាគតាមឯកសារពត៌មានស្ថានភាពឃុំ សង្កាត់ (បន្ត) |
| ១៥:០០-១៥:១៥ | សម្រាក |
| ១៥:១៥-១៧:៣០ | ជំហានទី១ : គ). ការកំណត់បញ្ហា តម្រូវការ និងដំណោះស្រាយឃុំ សង្កាត់ តាមរយៈបទពិសោធន៍ និងឧបករណ៍វិភាគផ្សេងៗ |
| ថ្ងៃទី២ | |
| ០៨:០០-១០:០០ | ជំហានទី២ : ការប្រជុំពិភាក្សាជាមួយប្រជាពលរដ្ឋក្នុងភូមិ |
| ១០:០០-១០:១៥ | សម្រាក |
| ១០:១៥-១២:០០ | ជំហានទី៣ : ការចាត់អាទិភាពដំណោះស្រាយនៅថ្នាក់ឃុំ សង្កាត់ |
| ១២:០០-១៤:០០ | សម្រាកពិសារបាយថ្ងៃត្រង់ |
| ១៤:០០-១៥:០០ | ជំហានទី៣ : ការចាត់អាទិភាពដំណោះស្រាយនៅថ្នាក់ឃុំ សង្កាត់ (បន្ត) |
| ១៥:០០-១៧:៣០ | ជំហានទី៤ : ការកំណត់ទិសដៅ និងយុទ្ធសាស្ត្រវិនិយោគ |
| ថ្ងៃទី៣ | |
| ០៨:០០-១០:០០ | ជំហានទី៥ : ការកំណត់គម្រោងដែលត្រូវវិនិយោគ |
| ១០:០០-១០:១៥ | សម្រាក |
| ១០:១៥-១០:៤៥ | ជំហានទី៦ : ការព្យាករណ៍ទុនវិនិយោគ |
| ១០:៤៥-១២:០០ | ជំហានទី៧ : ការរៀបចំតារាងគម្រោងវិនិយោគជាអាទិភាព |
| ១២:០០-១៤:០០ | សម្រាកពិសារបាយថ្ងៃត្រង់ |
| ១៤:០០-១៤:៤៥ | ជំហានទី៨ : សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ |
| ១៤:៤៥-១៧:៣០ | ជំហានទី៩ : ការសម្រេចចុងក្រោយលើគម្រោងនានាក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ |

| ពេលវេលា | កម្មវិធីបណ្តុះបណ្តាល |
|---|---|
| ថ្ងៃទី៤ | |
| ០៨:០០-០៩:៣០ | ជំហានទី៩ : ការសំរេចចុងក្រោយលើគំរោងនានាក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ (បន្ត) |
| ០៩:៣០-០៩:៤៥ | សំរាក |
| ០៩:៤៥-១២:០០ | ជំហានទី១០ : ការរៀងក្រងសៀវភៅកម្មវិធីវិនិយោគឃុំ សង្កាត់ |
| ១២:០០-១៤:០០ | សំរាកពិសារបាយថ្ងៃត្រង់ |
| ១៤:០០-១៥:៣០ | ជំហានទី១១ : ការរៀបចំអនុម័តឯកសារកម្មវិធីវិនិយោគឃុំ សង្កាត់ |
| ១៦:០០-១៧:០០ | ពិធីបិទវគ្គបណ្តុះបណ្តាល |

# ប្លង់មេរៀនជំហានទី១

## ក). ការកែសំរួល និងវិភាគផែនទីឃុំ សង្កាត់

គោលបំណង : សិក្ខាកាម អាចកែសំរួលផែនទីរបស់ខ្លួន និងមានការយល់ដឹងអំពីរបៀបប្រើប្រាស់ផែនទីសំរាប់ជាប្រភពក្នុងការកំណត់បញ្ហាឬតំរូវការ និងដំណោះស្រាយរបស់ឃុំ សង្កាត់ ។



រយៈពេល : ប្រហែល ២ម៉ោង



សំភារៈចាំបាច់ : ផែនទីដែលមានស្រាប់ ផែនទីដែលបានរៀបចំរួច និមិត្តសញ្ញាផែនទី ក្រដាសផ្ទាំងធំ ហ្វឺត និងស្កុត ។

វិធីសាស្ត្រ : បំផុសគំនិត ការពិភាក្សា ការបង្ហាញ និងបូកសរុប ។



កំណត់ចំណាំសំរាប់គ្រូឧទ្ទេស : អ្នកសំរបសំរួល ត្រូវដឹងអោយបានច្បាស់លាស់ថា និយមន័យនៃពាក្យ បញ្ហា តំរូវ និងដំណោះស្រាយ ក្នុងពេលនេះ គឺក្នុងបរិបទផែនការឃុំ សង្កាត់ ។ ពាក្យនីមួយៗ អាចមាននិយមន័យ ទូលំទូលាយជាងនេះ ។ ដូចនេះ អ្នកសំរបសំរួល ត្រូវក្តាប់អោយបាននូវការលើកឡើងរបស់សិក្ខាកាម ។

មេរៀននេះជាផ្នែកមួយនៃផ្នែកទាំងពាររបស់ជំហានទី១ ។ ផ្អែកតាមស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន អ្នកសំរបសំរួល ត្រូវរៀបចំនិមិត្តសញ្ញាផែនទីបន្ថែម បើចាំបាច់ ។

របៀបសំរបសំរួលមេរៀន :



១. មុនចូលដល់ការសំរបសំរួលក្នុងការកែសំរួលផែនទី អ្នកសំរបសំរួល ត្រូវបំផុសសំណួរ "តើពាក្យ បញ្ហា តំរូវការ និងដំណោះស្រាយ មានន័យយ៉ាងដូចម្តេច?" និងកត់ត្រាយោបល់ ឬចំលើយទាំងនោះ នៅលើក្រដាសផ្ទាំងធំ ។ បន្ទាប់មក អ្នកសំរបសំរួល បូកសរុបដោយបង្ហាញនិយមន័យនៃពាក្យទាំងនោះ និងលើកឧទាហរណ៍បញ្ជាក់ ។

| បញ្ហា | តំរូវការ | ដំណោះស្រាយ |
|---|---|---|
| និយមន័យ : | | |
| គឺជាឧបសគ្គ ឬចំណុចអវិជ្ជមានដែលបណ្តាលអោយរាំងស្ទះ ឬរំខានដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឬដំណើរការនៃការរីកចំរើន ។ | គឺជាអ្វីមួយដែលចាំបាច់ និងត្រូវធ្វើដើម្បីលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។ | គឺជាសកម្មភាព ឬមធ្យោបាយមួយក្នុងការដោះស្រាយបញ្ហា ឬបំពេញ ឬឆ្លើយតបទៅនឹងតំរូវការ ។ ដំណោះស្រាយជាអាទិភាព គឺជា |

| បញ្ហា | តំរូវការ | ដំណោះស្រាយ |
|---|---|---|
| | | ដំណោះស្រាយដែលអ្នកគិតថាមានសារៈសំខាន់ជាងដំណោះស្រាយមួយទៀត ហើយត្រូវបានអនុវត្តមុនគេ ។ |
| ឧទាហរណ៍ : | | |
| ខ្វះទឹកស្អាតប្រើប្រាស់ | ទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ | • ការជីក ឬជួសជុលអណ្តូងលូ<br>• ការជីក ឬជួសជុលអណ្តូងស្នប់<br>• ការជីក ឬស្តារស្រះភូមិ<br>• ប្រព័ន្ធទឹកស្អាត<br>• ប្រព័ន្ធចម្រោះទឹក |
| ទិន្នផលស្រូវទាប | បង្កើនទិន្នផលស្រូវ | • ការប្រើប្រាស់ជីកំប៉ុស្តិ៍<br>• ការប្រើប្រាស់ជីគីមី<br>• ការដាំដំណាំឆ្លាស់<br>• ការដាំដំណាំផ្តល់នូវជីជាតិដី<br>• ពូជដែលមានទិន្នផលខ្ពស់<br>• ការបណ្តុះបណ្តាលអំពីបច្ចេកទេសដាំដុះ<br>• ការតៀវពង្រាបដី និងបច្ចេកទេសគ្រប់គ្រងទឹក ។ |

២. ការកែសំរួលផែនទី : អ្នកសំរបសំរួល ត្រូវចាប់ផ្តើមដោយបំផុសគំនិតថា តើយើងប្រើប្រាស់ផែនទីនៅពេលណា? តើអ្វីខ្លះដែលត្រូវបញ្ចូលទៅក្នុងផែនទីឃុំ សង្កាត់? ។ អ្នកសំរបសំរួល កត់ត្រាចំលើយនៅលើក្រដាស់ផ្ទាំងធំ ហើយបន្ទាប់មក ត្រូវបង្ហាញ និងពន្យល់អំពីនិមិត្តសញ្ញាផែនទី ហើយសួរបន្ថែមថា តើយើងត្រូវការនិមិត្តសញ្ញាបន្ថែមសំរាប់ផែនទីរបស់យើងដែរឬទេ? ។ នៅលើផែនទី បើមានពត៌មានលំអិតស្អុតស្អាញពេក ឬមិនមានពត៌មានជាមូលដ្ឋានសំខាន់ៗទេ ផែនទីនោះមិនមានប្រយោជន៍ទេ នេះមានន័យថា ផែនទីត្រូវបញ្ចូលពត៌មាន និងនិមិត្តសញ្ញាសំខាន់ៗ អោយបានល្មមសមរម្យ ច្បាស់លាស់ និងមានប្រយោជន៍ ។

៣. អ្នកសំរបសំរួល ត្រូវបង្ហាញផែនទីឃុំ សង្កាត់មួយដែលមានត្រឹមតែព្រំប្រទល់ឃុំ សង្កាត់ ឬភូមិ និងផ្លូវប៉ុណ្ណោះ និងចែកផែនទីនេះ១ច្បាប់សំរាប់សិក្ខាកាម១ក្រុម (១ច្បាប់/ភូមិ) ។ បន្ទាប់មកក្រុមនីមួយៗបំពេញផែនទីនេះរៀងៗខ្លួន ដោយប្រើប្រាស់និមិត្តសញ្ញាដែលបានបង្ហាញខាងលើ ដូចជាសាលាឃុំ សង្កាត់ សាលារៀន មណ្ឌលសុខភាព តំបន់រស់នៅរបស់អ្នកភូមិ ស្ពាន ផ្លូវ លូ ស្ទឹង ទន្លេ បឹង ព្រៃឈើ ។ល។ បន្ទាប់ពីសិក្ខាកាមបំពេញរួច (ការបំពេញនេះត្រូវការពេលប្រហែល៥នាទី) អ្នកសំរបសំរួល ត្រូវបិទផែនទីនៅលើក្ដារខៀន ហើយបន្ទាប់មកអញ្ជើញសិក្ខាកាមអោយមកបំពេញម្នាក់មួយចំណុចៗ ។ សិក្ខាកាមដទៃទៀត អាចជួយពិនិត្យ និងកែតំរូវបន្ថែម ។ ម្យ៉ាងវិញទៀត អ្នកសំរបសំរួល អាចប្រើផែនទីដែលបានកែសំរួលឆ្នាំកន្លងទៅ ដើម្បីជាជំនួយក្នុងការកែសំរួលនេះ ។ មុននឹងបញ្ចប់ការកែសំរួលផែនទី អ្នកសំរបសំរួល ត្រូវបំផុសសំណួរដើម្បីផ្ទៀងផ្ទាត់ ដូចតទៅ :

- តើគំរោងដែលបានអនុវត្តឆ្នាំកន្លងទៅនៅកន្លែងណា?
- តើវាបានបញ្ចូលទៅក្នុង ផែនទីរួចហើយឬនៅ?
- តើយើងប្រើប្រាស់និមិត្តសញ្ញាណាមួយ?
- តើមានគំរោងថ្មីដទៃទៀត ឬមានការផ្លាស់ប្ដូរអ្វីកើតឡើងដែរឬទេ? ។

ការកែសំរួលផែនទី ត្រូវផ្អែកតាមពត៌មានដែលទទួលបាន ។ អ្នកសំរបសំរួល ត្រូវប្រាកដថាអ្នកចូលរួមទាំងអស់ ចូលរួមយ៉ាងសកម្ម ហើយតាមដានទូវអ្វីដែលបានកើតឡើង ។ ពត៌មានសំខាន់ៗមួយចំនួនអំពីស្ថានភាពឃុំ សង្កាត់ដែលរកឃើញនៅក្នុងកំឡុងពេលពិភាក្សា ត្រូវបញ្ចូលទៅក្នុងផែនទី ។

៤. ការវិភាគផែនទី : អ្នកសំរបសំរួល ត្រូវចាប់ផ្ដើមដោយលើកឡើងថា "ឥឡូវនេះយើងមានផែនទីដែលបានកែសំរួលរួចហើយ" ។ ដោយផ្អែកលើផែនទីនេះ យើងពិភាក្សាគ្នាអំពីចំងាយផ្លូវ និងរយៈពេលធ្វើដំណើរទៅទីតាំងសេវាកម្មនានា : តើមានចំងាយប៉ុន្មានពីភូមិនីមួយៗ និងចំណាយពេលប៉ុន្មានដើម្បីទៅកាន់ : សាលាបឋមសិក្សា មណ្ឌលសុខភាព កន្លែងប្រើប្រាស់ទឹក ផ្សារ សាលាឃុំសង្កាត់ ។ល។ ផ្អែកតាមការវិភាគនេះ តើមានបញ្ហា ឬតំរូវការសំខាន់ណាមួយដែរឬទេ? (ចូរគិតអំពីការ ជួសជុលផ្លូវសំណង់ និងបរិក្ខារសាធារណៈនានា អណ្ដូងឬស្រះទឹក ។ល។) ។ អ្នកសំរបសំរួល ត្រូវសរសេរបញ្ហា ឬតំរូវការទាំងនេះនៅលើក្រដាសផ្ទាំងធំ ហើយបន្ទាប់មកធ្វើការពិភាក្សារកដំណោះស្រាយ ។ ឥឡូវនេះ យើងពិនិត្យមើលធនធានធម្មជាតិ : ទន្លេ បឹង ស្ទឹង អូរ ព្រៃឈើ ។ល។

- តើទឹកស្ទឹង ឬអូរត្រូវបានប្រជាពលរដ្ឋប្រើប្រាស់ដែរឬទេ? តើទឹកនេះមានផ្ទុកដោយ

មេរោគដែលបណ្តាលអោយប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ នៅផ្នែកខាងក្រោមដែរឬ? តើវាបណ្តាលមកពីមូលហេតុអ្វី? ចូរកត់ត្រាតំរូវការទាំងនេះបើមាន ។

- តើតំបន់ព្រៃឈើនៅកន្លែងណាខ្លះ? តើព្រៃឈើទាំងនេះប្រើប្រាស់សំរាប់អ្វីខ្លះ? តើប្រជាពលរដ្ឋប៉ុន្មានគ្រួសារប្រើប្រាស់? តើព្រៃឈើមានការប្រែប្រួលដែរឬទេ នៅក្នុងកំឡុងពេល១ឆ្នាំកន្លងទៅ? ៥ឆ្នាំកន្លងទៅ? . តើវាប្រែប្រួលយ៉ាងដូចម្តេច? តើហេតុអ្វីបានជាវាប្រែប្រួល? ចូរកត់ត្រាតំរូវការទាំងនេះបើមាន ។
- លើកសំណួរដូចគ្នាសំរាប់បឹង ឬអាងស្តុកទឹកធំៗ ដោយបន្ថែមថា តើបឹងនេះប្រើប្រាស់សំរាប់សត្វដែរឬទេ?
- តើមានកន្លែងយកដីក្រហមនៅក្បែរនេះដែរឬទេ? បើប្រៀបធៀបទៅនឹងរយៈពេល៥ឆ្នាំមុនតើខុសគ្នាដូចម្តេចដែរ? តើហេតុអ្វីបានជាមានការប្រែប្រួលយ៉ាងដូចនេះ? តើការប្រែប្រួលនេះ នឹងបណ្តាលអោយមានបញ្ហាអ្វីទេ? ហើយ តើក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវដោះស្រាយយ៉ាងដូចម្តេច?
- តើមានប្រព័ន្ធធារាសាស្ត្រនៅក្បែរនេះដែរឬទេ? តើនរណាជាអ្នកប្រើប្រាស់ប្រព័ន្ធនេះ? ក្នុងគោលបំណងអ្វី? តើមានផលប៉ះពាល់អវិជ្ជមានដល់ប្រភពទឹកដែរឬទេ? តើមានផលប៉ះពាល់អវិជ្ជមានដល់ប្រជាពលរដ្ឋដែលមិនបានប្រើប្រាស់ប្រព័ន្ធនេះដែរឬទេ? ។ កត់ត្រានូវរាល់តំរូវការដែលបានមកពីការវិភាគនេះ ។
- តើមានភ្នំនៅក្បែរនេះដែរឬទេ? តើភ្នំត្រូវបានប្រើប្រាស់សំរាប់យកថ្មដែរឬទេ? តើមានផលប៉ះពាល់អ្វីខ្លះក្នុងការយកថ្មនេះដែរឬទេ? តើមានផលប៉ះពាលវិជ្ជមាន និងអវិជ្ជមានអ្វីខ្លះដល់ឃុំ សង្កាត់?

៥. អ្នកសំរបសំរួលសង្ខេបលទ្ធផលនៃការវិភាគ ដោយស្រង់បញ្ចូលទៅក្នុងតារាងជំនួយស្មារតីទី១ ។

## កំណត់សំគាល់

ដើម្បីភាពងាយស្រួល គួរប្រើប្រាស់សញ្ញាសំគាល់ឯកភាពមួយចំនួន ក្នុងការគូរផែនទីឃុំសង្កាត់ សញ្ញាសំគាល់ដែលជូនភ្ជាប់មកជាមួយនេះ គឺជាសំគាល់ផ្តល់ដោយក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ ។

| សញ្ញា | អត្ថន័យ | សញ្ញា | អត្ថន័យ |
|---|---|---|---|
| | សាលាខេត្ត សាលាក្រុង | | ព្រំប្រទល់ប្រទេស |
| | សាលាស្រុក សាលាខ័ណ្ឌ | | ព្រំប្រទល់ខេត្ត |
| | សាលារៀន | | ព្រំប្រទល់ស្រុក |
| | វត្ត | | ព្រំប្រទល់ឃុំ |
| | វិហារកាតូលិក វិហារឥស្លាម | | ថ្នល់កៅស៊ូទទឹង៥មឡើងទៅ |
| | ប្រៃសនីយ៍ មន្ទីរពេទ្យ | | ថ្នល់កៅស៊ូទទឹង២,៥ម |
| | ក)វាលស្រែ ខ)វាលស្រែលិចទឹក | | ថ្នល់ក្រាលថ្មទទឹង៥មឡើងទៅ |
| | ក)ចំការ ខ)ដំណាំក្នុងភូមិ | | ថ្នល់ក្រាលថ្មទទឹង២,៥ម |
| | ចំការដំណាំ | | ផ្លូវលំ ផ្លូវក្រាយ តូចជាង២,៥ម |
| | ចំការឈើហូបផ្លែ | | ផ្លូវជើង |
| | កសិកម្មពនេចរ | | ទន្លេ ស្ទឹង ព្រែក មានទឹកខួប |
| | ដើមត្នោតដុះរាត់រាយ | | ទន្លេ ស្ទឹង ព្រែក ទឹកមិនខួប |
| | ក)ព្រៃក្រាស់ ខ)ព្រៃស្តើង | | ក) បឹង ត្រពាំង មានទឹកខួប |
| | វាលស្មៅលិចទឹក | | ខ) បឹង ត្រពាំង មានទឹកមិនខួប |
| | ព្រៃគុម្ពោតលិចទឹក | | ស្ពានថ្មើជើង |
| | ព្រៃលិចទឹក | | កំពង់ផែ កំពង់សាឡាង |
| | ក)ទំនាបបឹង ខ)ព្រៃកោងកាង | | ស្ពាន |

# ប្លង់មេរៀនជំហានទី១

## ១). ការវិភាគតាមឯកសារពត៌មានស្ថានភាពឃុំ សង្កាត់

គោលបំណង : សិក្ខាកាម យល់ដឹងអំពីរបៀបវិភាគពតិមានស្ថានភាពឃុំ សង្កាត់ ដើម្បីកំណត់បញ្ហាឬតំរូវការរបស់ឃុំ សង្កាត់ ។ សិក្ខាកាម អាចពន្យល់ដល់ គ.ជ.ថ អំពីរបៀបប្រើប្រាស់ពតិមានស្ថានភាពឃុំ សង្កាត់របស់ខ្លួន និងអាចដឹកនាំ គ.ជ.ថ ក្នុងការវិភាគឯកសារពតិមានស្ថានភាព ឃុំ សង្កាត់ ។



រយៈពេល : ប្រហែល២ម៉ោង



សំភារៈចាំបាច់ : ឯកសារពតិមានស្ថានភាពឃុំ សង្កាត់ ក្រដាសផ្ទាំងធំ ស្កត់ និងហ្វឹត ។

វិធីសាស្ត្រ : បំផុសគំនិត ការពិភាក្សា ការបង្ហាញ និងបូកសរុប ។



កំណត់ចំណាំសំរាប់គ្រូឧទ្ទេស : មេរៀននេះជាផ្នែកមួយនៃផ្នែកទាំង៣របស់ជំហានទី១ ។ ចំពោះការបណ្តុះបណ្តាលអ្នកសំរបសំរួល ចាំបាច់ត្រូវមានការរៀបចំអោយបានល្អិត និងដោយប្រុងប្រយ័ត្ន ។ នៅថ្នាក់ឃុំ សង្កាត់ ការរៀបចំនេះ មានលក្ខណៈងាយស្រួលជាង ពីព្រោះយើងអាចបត់បែនបានទៅតាមស្ថានភាពជាក់ស្តែងរបស់ឃុំ សង្កាត់ ។

របៀបសំរបសំរួលមេរៀន :



១. អ្នកសំរបសំរួល ចែកឯកសារពតិមានស្ថានភាពឃុំ សង្កាត់អោយសិក្ខាកាមគ្រប់គ្នា (អ្នកសំរបសំរួលខេត្តក្រុង និងស្រុកខណ្ឌ) ។ ឯកសារពតិមានស្ថានភាពឃុំ សង្កាត់នេះ គឺជាឯកសារពតិមានស្ថានភាពជាក់ស្តែងរបស់ឃុំ សង្កាត់ណាមួយ ។

២. អ្នកសំរបសំរួល ចាប់ផ្តើមពិភាក្សាយឺតៗអំពីពតិមានស្ថានភាពឃុំ សង្កាត់ ជាមួយសិក្ខាកាម ដោយផ្អែកលើសំណួរគន្លឹះដែលមាននៅខាងក្រោមក្រាភិចនីមួយៗ ។ អ្នកសំរបសំរួល :

- ត្រូវប្រាកដថា សិក្ខាកាមបានបើកឯកសារចំទំព័រត្រឹមត្រូវ ។
- ត្រូវប្រាកដថាសិក្ខាកាមយល់អំពីខ្លឹមសារ (សួរសំណួរទៅកាន់សិក្ខាកាមអំពីបញ្ហានានាដែលអ្នកបានពន្យល់ អនុញ្ញាតអោយសិក្ខាកាមលើកឡើងនូវឧទាហរណ៍ និងសំណួរ) ។
- ត្រូវប្រាកដថា សិក្ខាកាមទាំងអស់បានចូលរួម (មិនត្រូវសួរទៅកាន់សិក្ខាកាមអ្នកដដែលៗទេ) ។
- មិនត្រូវពន្យល់ ឬបង្រៀនលឿនពេក (វាមិនមានបញ្ហាអ្វីទេ បើអ្នកលើកឡើងនូវ

អ្វីមួយម្តងជាពីរដង) ។

- ពិនិត្យមើលសិក្ខាកាម ថាតើពួកគេយល់អំពីភាគរយ (%)ដែរឬទេ? ។ ឧទាហរណ៍ : នៅក្នុងបន្ទប់បណ្តុះបណ្តាលនេះ មានសិក្ខាកាមចំនួន៣០នាក់ ។ សិក្ខាកាមចំនួន៤០% មិនយល់អំពីអ្វីដែលកំពុងបរិយាយនេះទេ តើចំនួន៤០%នេះ ស្មើនឹងចំនួនប៉ុន្មាននាក់? ។

៣. ក្រាភិច : មុននឹងសួរសំណួរបែបវិភាគ អ្នកសំរបសំរួល ត្រូវពិនិត្យមើល តើសិក្ខាកាមយល់អំពីរបៀបមើល (អាន) ក្រាភិច? "តើភូមិណាមួយដែលមានភាគរយចំនួនសត្វគោក្នុងមួយគ្រួសារទាបជាងគេ?" ។ អ្នកសំរបសំរួល ត្រូវប្រាកដថា សិក្ខាកាមទាំងអស់អាចឆ្លើយនូវសំណួរសាមញ្ញៗបែបនេះ ។

៤. អ្នកសំរបសំរួល ធ្វើការវិភាគរួមជាមួយសិក្ខាកាម តាមរយៈសំណួរបែបវិភាគ ទៅលើឯកសារពត៌មានស្ថានភាពឃុំ សង្កាត់ ដើម្បីកំណត់បាននូវបញ្ហា ឬតំរូវការ និងដំណោះស្រាយរបស់ឃុំ សង្កាត់ ។

៥. ការបំផុសគំនិត : អ្នកសំរបសំរួល បន្តការងារជាមួយសិក្ខាកាម ដោយលើកឡើងនូវសំណួរថា "តើត្រូវធ្វើការវិភាគឯកសារពត៌មានស្ថានភាពឃុំ សង្កាត់ជាមួយ គ.ផ.ថ យ៉ាងដូចម្តេច?" ។ អ្នកសំរបសំរួល កត់ចំលើយ និងមតិយោបល់នានារបស់សិក្ខាកាម នៅលើក្រដាសផ្ទាំងធំ ។

ការសង្កេតរបស់អ្នកសំរបសំរួល : តាមកំរិតវប្បធម៌និងចំណេះដឹងរបស់ គ.ផ.ថ នៅពេលបច្ចុប្បន្ន យើងមិនសង្ឃឹមថា គ.ផ.ថ អាចធ្វើការវិភាគឯកសារពត៌មានស្ថានភាពឃុំ សង្កាត់ ដោយខ្លួនឯងបានទេ ។ យើងក៏មិនអាចសង្ឃឹមថា សមាជិក គ.ផ.ថ ទាំងអស់យល់ពេញលេញអំពីការវិភាគទិន្នន័យនៃពត៌មានស្ថានភាពឃុំ សង្កាត់ និងក្រាភិចដែរ ។ ដូចនេះ យើងត្រូវព្យាយាមពន្យល់ គ.ផ.ថ យឺតៗតាមរយៈការអាន ការពន្យល់ម្តងហើយម្តងទៀត និងខិតខំអោយអស់សមត្ថភាពដើម្បីអោយ គ.ផ.ថ យល់បន្តិចម្តងៗ ។ អ្នកសំរបសំរួល មិនត្រូវនិយាយថា "ខ្ញុំបានវិភាគឯកសារពត៌មានស្ថានភាពឃុំ សង្កាត់របស់អ្នករួចហើយ នេះគឺជាបញ្ហា តំរូវការ និងដំណោះស្រាយរបស់អ្នក : ១. ២. ៣ ។ល។

៦. បញ្ហា តំរូវការ និងដំណោះស្រាយដែលបានកំណត់តាមរយៈការវិភាគឯកសារពត៌មានស្ថានភាពឃុំ សង្កាត់ ត្រូវកត់ត្រាទៅលើក្រដាសផ្ទាំងធំ បន្ទាប់មកស្រង់បញ្ចូលតារាងជំនួយស្មារតីទី១ ។

## ប្លង់មេរៀនជំហានទី១

## គ). ការកំណត់បញ្ហា តំរូវការ និងដំណោះស្រាយឃុំ សង្កាត់ តាមរយៈបទពិសោធន៍ និងឧបករណ៍វិភាគផ្សេងៗទៀត

គោលបំណង : សិក្ខាកាម យល់ដឹង និងអាចបំផុសសំណួរដល់ គ.ជ.ថ ក្នុងការកំណត់បញ្ហា តំរូវការ និងដំណោះស្រាយបន្ថែម តាមរយៈវិធីសាស្ត្រដែលមានការចូលរួម ។



រយៈពេល : ប្រហែល១ម៉ោង



សំភារៈចាំបាច់ : ក្រដាសផ្ទាំងធំ ស្កត់ ហ្វឺត និងតារាងរជំនួយស្មារតីទី១ ។

វិធីសាស្ត្រ : បំផុសគំនិត ការពិភាក្សា ការបង្ហាញ និងបូកសរុប ។



កំណត់ចំណាំសំរាប់គ្រូឧទ្ទេស : នៅផ្នែកនេះ វាជាការសំខាន់ណាស់ ដែលត្រូវលើកឡើងអោយបានច្រើននូវតំរូវការផ្នែកសង្គមដូចតំរូវការផ្នែកហេដ្ឋារចនាសម្ព័ន្ធដែរ ។ អ្នកសំរបសំរួលត្រូវជំរុញការពិភាក្សាអោយបានខ្លាំងក្លាតាមអាចធ្វើទៅបាន ហើយប្រាកដថា សិក្ខាកាមទាំងអស់ (គ.ជ.ថ) មានឱកាសគ្រប់គ្រាន់ក្នុងការលើកឡើងនូវមតិយោបល់របស់ខ្លួន ។

អ្នកសំរបសំរួល ក៏អាចប្រើប្រាស់ឧបករណ៍វិភាគផ្សេងៗទៀត ដើម្បីកំណត់បញ្ហា តំរូវការ និងដំណោះស្រាយ ដូចជាឧបករណ៍វិភាគធនធានធម្មជាតិនិងបរិស្ថាន និងយេនឌ័រ ជាដើម ។

របៀបសំរបសំរួលមេរៀន :



១. អ្នកសំរបសំរួលចាប់ផ្តើមដោយលើកឡើងថា "ឥឡូវនេះ តាមរយៈផែនទី និងឯកសារពត៌មានស្ថានភាពឃុំ សង្កាត់ យើងបានកំណត់បញ្ហា តំរូវការ និងដំណោះស្រាយមួយចំនួនហើយ" ។ ដោយបង្ហាញតារាង ជំនួយស្មារតីទី១ដែលបានកត់ត្រា បញ្ហា តំរូវការ និងដំណោះស្រាយ ទាំងនោះ អ្នកសំរបសំរួល លើកសំណួរថា "តើមានបញ្ហា តំរូវការ និងដំណោះស្រាយអ្វីផ្សេងទៀត ដែលមិនទាន់បានលើកឡើងដែរឬទេ? ។ ការប្រើប្រាស់ផែនទី ឬឯកសារពត៌មានស្ថានភាពឃុំ សង្កាត់ ជារឿយៗ យើងអាចរកឃើញតែបញ្ហា តំរូវការ និងដំណោះស្រាយដែលជារបស់មើលឃើញដោយ ភ្នែកប៉ុណ្ណោះ ប៉ុន្តែវាអាចមានបញ្ហា តំរូវការ និងដំណោះស្រាយជាច្រើនទៀត" ។ ប្រសិនបើ គ.ជ.ថ មិនអាចលើកឡើងនូវមតិយោបល់អ្វីទេនោះ អ្នកសំរបសំរួល អាចបំផុស គំនិតថា "សូមគិតគូរអំពីបញ្ហា ឬ

តំរូវការ ដែលអ្នកនិងប្រជាពលរដ្ឋនៅក្នុងភូមិរបស់អ្នក នឹងត្រូវដោះស្រាយ ដូចជា បញ្ហា ឬតំរូវការផ្នែកសុខភាព ការអប់រំកូនចៅរបស់អ្នក ប្រជាពលរដ្ឋដែលក្រីក្រនិងងាយរងគ្រោះបំផុត បញ្ហាឬតំរូវការពិសេសសំរាប់ស្ត្រី កុមារ ជនជាតិដើមភាគតិច ។ល។

ឧទាហរណ៍អំពីបញ្ហា តំរូវការ និងដំណោះស្រាយមួយចំនួន :

| | |
|---|---|
| • សេវាសុខភាពនៅក្នុងភូមិជាប្រចាំ | • អំពើហិង្សាក្នុងគ្រួសារ និងផលប៉ះពាល់លើការអភិវឌ្ឍន៍របស់កុមារ |
| • ការពន្យារកំណើត | • អត្រាការប្រាក់ទាបនៅមូលដ្ឋាន |
| • មាតុភាពគ្មានគ្រោះថ្នាក់ | • ការបណ្តុះបណ្តាលវិជ្ជាជីវៈសំរាប់ស្ត្រី |
| • ការការពារទប់ស្កាត់នឹងមេរោគ/ជំងឺអេដស៍ និងការថែទាំអ្នកផ្ទុកមេរោគអេដស៍ | • ការប្រើប្រាស់ជាតិស្រវឹង និងគ្រឿងញៀន |
| • ការអប់រំសុខភាព និងអាហារូបត្ថម្ភ | • ការបណ្តុះបណ្តាលក្រុមប្រើប្រាស់ទឹកអំពីអនាម័យ និងការប្រើប្រាស់ទឹក ។ |
| • ការអប់រំអនាម័យ | • ការបណ្តុះបណ្តាលអំពីវិធានការចំរុះការពារដំណាំសំរាប់សិស្សអក្ខរកម្ម |
| • ការប្រើប្រាស់បង្គន់អនាម័យតាមគ្រួសារ | • ការលាងសំអាតដៃ និងអនាម័យទូទៅ |
| • ក្រុមប្រើប្រាស់អណ្តូងទឹក | • ការផ្សព្វផ្សាយអំពីការបំបៅដោះដោយទឹកដោះម្តាយ អាហារបន្ថែម អំបិលអ៊ីយ៉ូត ការត្រួតពិនិត្យជំងឺ ផលវិបាកនៃការព្យាបាលជំងឺនៅតាមផ្ទះ |
| • ការរៀបចំសួនបន្លែតាមផ្ទះ | • សហគមន៍ជួយដល់ជនងាយរងគ្រោះ |
| • អក្ខរកម្ម និងបំនិនជីវិត | • ការបណ្តុះបណ្តាលអំពីការធ្វើ និងប្រើប្រាស់ជីកុំប៉ុស្តិ៍ |
| • មត្តេយ្យសាលា និងការថែទាំសុខភាពកុមារ | • ការបណ្តុះបណ្តាលអំពីសិទ្ធិកុមារ ស្ត្រី និងមនុស្សទូទៅ |
| • ភាពងាយស្រួលក្នុងការទទួលបានសំបុត្រកំណើត | |
| • វគ្គបណ្តុះបណ្តាលស្តីពីការយល់ដឹងពីអំពើហិង្សាក្នុងគ្រួសារ | |
| • កិច្ចការពារកុមារដែលគ្រួសារមានជំងឺរ៉ាំរ៉ៃ | |

ឧទាហរណ៍ខាងលើនេះ គឺគ្រាន់តែជាជំនួយសំរាប់ជួយដល់អ្នកសំរបសំរួល ក្នុងពេលសំរបសំរួលបញ្ហា ឬតំរូវការ ឬដំណោះស្រាយផ្នែកសង្គម និងផ្នែកដទៃទៀត ។

២. រាល់បញ្ហា តំរូវការ និងដំណោះស្រាយដែលបានលើកឡើង ត្រូវកត់ត្រាបញ្ចូលបន្ថែមទៅក្នុងតារាងជំនួយស្មារតីទី១ ។

៣. អ្នកសំរបសំរួល បញ្ចប់ផ្នែកនេះ ដោយបង្ហាញបញ្ហា ឬតំរូវការនៅឆ្នាំកន្លងទៅ (បើមាន) ដើម្បីប្រៀបធៀប ថាតើមានបញ្ហា ឬតំរូវការឆ្នាំចាស់ដែលមិនមាននៅក្នុងបញ្ជីបញ្ហា ឬតំរូវការឆ្នាំថ្មីនេះ ដែរឬទេ? ហេតុអ្វី? ។

៤. ការពង្រឹងសមត្ថភាពតំណាងភូមិសំរាប់អនុវត្តជំហានទី២ :

អ្នកសំរបសំរួល ត្រូវពន្យល់អំពីកិច្ចការនានាដែលត្រូវអនុវត្តនៅជំហានទី២ ។ ដើម្បីពន្យល់អំពីរបៀបធ្វើកិច្ចការនេះ អ្នកសំរបសំរួល ត្រូវអានឯកសារណែនាំបច្ចេកទេសសំរាប់អ្នកសំរបសំរួលដំណើរការរៀបចំកម្មវិធីវិនិយោគពាក្យវិកិលរបស់ឃុំ សង្កាត់ដោយប្រុងប្រយ័ត្ន ។ អ្នកសំរបសំរួល ត្រូវពន្យល់តំណាងភូមិ អំពីគោលបំណង និងវិធីសាស្ត្រនៃការអនុវត្តការពិភាក្សាជាមួយអ្នកភូមិ ។ ជំហាននេះ គឺជាជំហានដ៏សំខាន់បំផុតដែលអ្នកភូមិមានឱកាសផ្ទាល់ក្នុងការផ្តល់មតិយោបល់ ទៅលើដំណើរការកសាងកម្មវិធីវិនិយោគពាក្យវិកិលរបស់ខ្លួន ។

# ប្លង់មេរៀនជំហានទី២
# ការប្រជុំពិភាក្សាជាមួយប្រជាពលរដ្ឋក្នុងភូមិ

គោលបំណង : សិក្ខាកាម បានយល់អំពីរបៀបណែនាំដល់ គ.ផ.ថ ក្នុងការរៀបចំ និងដឹកនាំការប្រជុំភូមិប្រកបដោយប្រសិទ្ធភាព និងមានការចូលរួមយ៉ាងពេញលេញ ។

រយៈពេល : ប្រហែល២ម៉ោង

សំភារៈចាំបាច់ : បញ្ជីសង្ខេតការប្រជុំ ក្រដាសផ្ទាំងធំ ស្កុត និងហ្វឺត ។

វិធីសាស្ត្រ : ការបំផុសគំនិត ការសំដែងតួ និងបូកសរុប ។

កំណត់ចំណាំសំរាប់គ្រូឧទ្ទេស : នៅផ្នែកនេះ វាជាការសំខាន់ណាស់ ដែលត្រូវលើកឡើងអោយបានច្រើននូវតំរូវការផ្នែកសង្គមដូចតំរូវការផ្នែកហេដ្ឋារចនាសម្ព័ន្ធដែរ ។ អ្នកសំរបសំរួលត្រូវជំរុញការពិភាក្សាអោយបានខ្លាំងក្លាតាមដែលអាចធ្វើទៅបាន ហើយប្រាកដថា សិក្ខាកាមទាំងអស់មានឱកាសគ្រប់គ្រាន់ក្នុងការលើកឡើងនូវមតិយោបល់របស់ខ្លួន។ អ្នកសំរបសំរួលត្រូវយល់អោយបានពេញលេញនូវគោលការណ៍សំខាន់ៗនៃការប្រជុំភូមិ ដែលជាផ្នែកមួយសំខាន់នៅក្នុងដំណើរការកសាងផែនការ ។ អ្នកសំរបសំរួលស្រុក ខណ្ឌ ត្រូវជំរាបដល់តំណាងភូមិដែលជា គ.ផ.ថ ថា មុនចាប់ផ្តើមដំណើរការប្រជុំ តើអ្នកភូមិបានមកចូលរួមតាមចំនួនកំណត់ហើយឬនៅ? (ចំនួន៦០-៧០%) ។

របៀបសំរបសំរួលមេរៀន :

១. ការបំផុសគំនិត : តើអ្វីខ្លះដើម្បីធ្វើអោយការប្រជុំភូមិមានប្រសិទ្ធភាព និងជោគជ័យ? ។ អ្នកសំរបសំរួល ត្រូវកត់ត្រានូវរាល់មតិយោបល់ដែលបានលើកឡើងដោយអ្នកចូលរួមនៅលើក្រដាសផ្ទាំងធំ ។ ខាងក្រោមនេះ អាចជាចំលើយមួយចំនួន :

- ការប្រជុំត្រូវរៀបចំនៅកន្លែងស្ងាត់ (មិនអ៊ូអរ) និងមានម្លប់ត្រជាក់ ។
- ប្រជាពលរដ្ឋអាចស្តាប់ឮ និងមើលគ្នាឃើញទៅវិញទៅមក ។
- អ្នកសំរបសំរួលមានជំនាញសំរបសំរួលល្អ ។
- ជ្រើសរើសពេលវេលាប្រជុំសមស្របសំរាប់អ្នកចូលរួម ។
- រៀបចំឯកសារដែលត្រូវការ ។
- ការពិភាក្សាដោយសេរី និងបើកចំហ (មិនមានវិវាទ) ។

- អ្នកចូលរួមមានឱកាសបញ្ចេញមតិយោបល់ ។
- គ្មានបុគ្គលណាមួយ លុបលើការប្រជុំ ។

២. ការសំដែងតួ : អ្នកសំរបសំរួល រៀបចំសិក្ខាកាមដូចខាងក្រោម :

- សិក្ខាកាម៦នាក់ សំដែងតួជាអ្នកសង្កេតការណ៍ ។ អ្នកសង្កេតការណ៍ ប្រើបញ្ជីត្រួតពិនិត្យ (មានភ្ជាប់មកជាមួយ) ដើម្បីវាយតំលៃការប្រជុំ ។
- សិក្ខាកាម២នាក់ (ស្ត្រីម្នាក់ និងបុរសម្នាក់) សំដែងតួជាតំណាងភូមិនៃ គ.ជ.ថ ដើម្បីសំរបសំរួលការប្រជុំភូមិ ។
- សិក្ខាកាមដទៃទៀត សំដែងតួជាអ្នកភូមិ (ត្រូវប្រាកដថាមានស្ត្រីគ្រប់គ្រាន់ដើរតួជាអ្នកភូមិ បើពុំមានគ្រប់គ្រាន់ទេ ត្រូវចាត់តាំងបុរសខ្លះអោយដើរតួជាស្ត្រី) ។ សិក្ខាកាមទាំងនេះ ត្រូវបែងចែកជា២ក្រុមស្មើគ្នា ។

ក្រុមពិភាក្សាទាំង២ ត្រូវផ្តោតការពិភាក្សាទៅលើបញ្ហា តំរូវការ និងដំណោះស្រាយរបស់ភូមិទាំងមូល មិនមែនក្រុមមួយផ្តោតការពិភាក្សាទៅលើបញ្ហា តំរូវការ និងដំណោះស្រាយជាក់លាក់របស់បុរស ឬស្ត្រី និងក្រុមភាគតិចណាមួយនោះទេ ។ ក្រុមពិភាក្សានីមួយៗ មិនចាំបាច់បង្ហាញលទ្ធផលរបស់ក្រុមខ្លួនទេ ដោយគ្រាន់តែបិទលទ្ធផលទាំងនោះនៅលើក្តារខៀន ។ បន្ទាប់មក អ្នកសំរបសំរួល ធ្វើការបូកសរុប ។

៣. បន្ទាប់មក អ្នកសំរបសំរួល ត្រូវបិទបញ្ជីសង្កេតនៅលើក្តារខៀន ។ អ្នកសង្កេតការណ៍ ត្រូវលើកឡើងមួយចំណុចម្តងៗ ។ អ្នកសំរបសំរួល កត់ត្រាការសង្កេត និងពិនិត្យឡើងវិញមួយចំណុចម្តងៗ ។ នៅត្រង់នេះ អ្នកសំរបសំរួល មានឱកាសដើម្បីលើកឡើងនូវចំណុចសំខាន់នានានៃការប្រជុំភូមិ ។

៤. អ្នកសំរបសំរួល បន្ថែមថា ជាទូទៅមានបញ្ហាឬតំរូវការផ្នែកសង្គមជាច្រើនដែលជាញឹកញាប់អ្នកភូមិមិនបានលើកឡើង ។ ហេតុអ្វីដែលអ្នកភូមិមិនបានលើកឡើងពីតំរូវការទាំងនេះ? តើអ្នកសំរបសំរួលស្រុក ខណ្ឌ ត្រូវធ្វើ ឬបំផុសសំណួរដូចម្តេចដើម្បីអោយបញ្ហាទាំងនេះត្រូវបានលើកឡើង? រាល់ចំលើយត្រូវសរសេរនៅលើក្រដាសផ្ទាំងធំ ។

៥. អ្នកសំរបសំរួល បញ្ចប់មេរៀននេះ ដោយបង្ហាញតាមលំដាប់លំដោយនូវខ្លឹមសារនៃជំហានទី២ដល់សិក្ខាកាម (ខ្លឹមសារមាននៅក្នុងឯកសារណែនាំបច្ចេកទេស) ។

## តារាងជំនួយស្មារតីទី២

| ប្រធានបទដែលបានពិភាក្សា | | ដំណោះស្រាយ | អាទិភាព | យោបល់ឯកភាព របស់ជនជាតិដើមភាគតិច |
|---|---|---|---|---|
| បញ្ហា | តំរូវការ | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

## បញ្ជីសំណួរសំរាប់សង្កេតការណ៍

| លរ | សំណួរ | បាទ | ទេ | យោបល់ផ្សេងៗ |
|---|---|---|---|---|
| ១ | តើការប្រជុំរៀបចំនៅកន្លែងសមរម្យដែរឬទេ? (កន្លែងស្អាតល្អ និងមានម្លប់) | | | |
| ២ | តើពេលវេលាប្រជុំសមស្របដែរឬទេ? | | | |
| ៣ | តើបានរៀបចំឯកសារដែលត្រូវការទាំងអស់ដែរឬទេ? | | | |
| ៤ | តើតំណាងគ្រួសារមកចូលរួមបានគ្រប់ចំនួនដែលបានកំណត់ដែរឬទេ? | | | |
| ៥ | តើអ្នកសំរបសំរួល មានជំនាញក្នុងការសំរបសំរួលល្អដែរឬទេ? | | | |
| ៦ | តើអ្នកភូមិយល់ច្បាស់អំពីបញ្ហានានាដែរឬទេ? | | | |
| ៧ | តើមានអ្នកណាម្នាក់លុបលើការប្រជុំដែរទេឬ? | | | |
| ៨ | តើអ្នកចូលរួមទាំងអស់មានឱកាសនិយាយដែរឬទេ? | | | |
| ៩ | តើអ្នកចូលរួមទាំងអស់ បាននិយាយដែរឬទេ? | | | |
| ១០ | តើការពិភាក្សាបើកចំហរ និងសេរីដែរឬទេ? | | | |

# ប្លង់មេរៀនជំហានទី៣
## ការចាត់អាទិភាពដំណោះស្រាយនៅថ្នាក់ឃុំ សង្កាត់



គោលបំណង : សិក្ខាកាម យល់ច្បាស់អំពីរបៀបបូកសរុបដំណោះស្រាយដែលបានកំណត់នៅជំហានទី១និងជំហាទី២ និងចាត់អាទិភាពដំណោះស្រាយទូទាំងឃុំ សង្កាត់ ។



រយៈពេល : ប្រហែល៣ម៉ោង



សំភារៈចាំបាច់ : ក្រដាសផ្ទាំងធំ ស្កត់ ហ្វឺត លទ្ធផលជំហានទី១ និងទី២ លំហាត់ និងតារាងជំនួយស្មារតីទី៣.១ និង៣.២ ។

វិធីសាស្រ្ត : ការបង្ហាញ លំហាត់ ការបូកសរុប និងឆ្លុះបញ្ចាំង ។



កំណត់ចំណាំសំរាប់គ្រូឧទ្ទេស : ការចាត់អាទិភាពដំណោះស្រាយនៅជំហាននេះ មានសារៈសំខាន់ណាស់ ហើយវាជាការចាត់អាទិភាពចុងក្រោយបំផុត នៅក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគពីរឆ្នាំរំកិលរបស់ឃុំ សង្កាត់ ។ ដូចនេះ អ្នកសំរបសំរួលស្រុក ខណ្ឌ ត្រូវព្យាយាមជួយដល់ គ.ជ.ឋ ក្នុងការចាត់អាទិភាពអោយបានសុក្រិត្យបំផុត តាមអាចធ្វើទៅបាន ។
អ្នកសំរបសំរួល ត្រូវបញ្ជាក់ដល់មេឃុំ ចៅសង្កាត់ផងដែរថា ជនបង្គោលទទួលបន្ទុកកិច្ចការស្រ្តី និងកុមារ នឹងចូលរួមក្នុងការពិភាក្សានៅជំហាននេះ ។

របៀបសំរបសំរួលមេរៀន :



១. អ្នកសំរបសំរួល រំលឹកឡើងវិញយ៉ាងសង្ខេប នូវអ្វីៗដែលបានធ្វើនៅជំហានទី១ និងទី២ ។ "នៅពេលនេះ យើងមានបញ្ជីបញ្ហា តំរូវការ និងដំណោះស្រាយនៅថ្នាក់ឃុំ និងភូមិ ។ នៅផ្នែកនេះ យើងនឹងបូកសរុបលទ្ធផលនៃជំហានទី១ និងទី២ ហើយធ្វើការចាត់អាទិភាពដំណោះស្រាយ" ។

២. អ្នកសំរបសំរួល ពន្យល់ តារាងជំនួយស្មារតីទី៣.១ ព្រមទាំងលើកឧទាហរណ៍បញ្ជាក់ ។ នៅក្នុងការបំពេញតារាងជំនួយស្មារតីទី៣.១ ត្រូវធ្វើឡើងមួយភូមិម្តងៗ ដោយបញ្ជាក់ពីកំរិតអាទិភាពអោយបានច្បាស់ ដូចជា "ខ : ខ្ពស់" "ម : មធ្យម" និង "ទ : ទាប" មិនមែនគ្រាន់តែគូសសញ្ញា "✓" នោះទេ ។ បន្ទាប់មក ភូមិទី២ បញ្ចូលបន្ថែមដំណោះស្រាយរបស់ខ្លួនដែលភូមិទី១ មិនបានលើកឡើង ។ ចំពោះដំណោះស្រាយណាដែលភូមិទី១បានលើករួចមកហើយ មិនចាំបាច់លើកមកទៀតទេ ដោយគ្រាន់តែបញ្ជាក់អំពីកំរិតអាទិភាពនៃដំណោះស្រាយភូមិរបស់ខ្លួនប៉ុណ្ណោះ ។ ធ្វើបែបនេះរហូតដល់គ្រប់ភូមិ ។

បន្ទាប់មក អ្នកសំរបសំរួល ត្រូវពន្យល់អំពី របៀបផ្តល់ពិន្ទុ និងវិធីសាស្ត្រគណនា :

- ដាក់ពិន្ទុនៃអាទិភាពដែលអ្នកភូមិបានកំណត់នីមួយៗ តាមចំនួន ដូចតទៅ "ខ្ពស់=៣" "មធ្យម=២" និង "ទាប=១" ។ បន្ទាប់មកបូកសរុបចំនួនពិន្ទុទាំងនោះ ហើយចែកនឹងចំនួនភូមិសរុប យើងបានពិន្ទុ "ទូទាំងឃុំ សង្កាត់"
- ការដាក់ពិន្ទុរបស់ គ.ផ.ថ ដោយផ្អែកតាមភាពចាំបាច់នៃដំណោះស្រាយនីមួយៗ តាមចំនួនពិន្ទុ "ចាំបាច់ណាស់=៣" "ចាំបាច់បង្គួរ=២" និង "មិនចាំបាច់=១"
- ពិន្ទុសរុប = ពិន្ទុទូទាំងឃុំសង្កាត់ + ពិន្ទុភាពចាំបាច់ ។ ផ្អែកតាមពិន្ទុសរុបនេះ អ្នកសំរបសំរួល ជាមួយសិក្ខាកាម ធ្វើការចាត់អាទិភាពដំណោះស្រាយ ។ វិធីសាស្ត្រចាត់អាទិភាពសូមអានឯកសារណែនាំបច្ចេកទេស ។

៣. អ្នកសំរបសំរួល ពន្យល់ តារាងជំនួយស្មារតីទី៣.២ ព្រមទាំងលើកឧទាហរណ៍បញ្ជាក់ បន្ទាប់មក ត្រូវបញ្ជាក់ដល់សិក្ខាកាមអោយបានច្បាស់ថា ដំណោះស្រាយទាំងអស់ គឺជាដំណោះស្រាយរបស់ឃុំ សង្កាត់ ។ រាល់ដំណោះស្រាយទាំងនោះ ត្រូវរៀបចំតាមលំដាប់លំដោយនៃអាទិភាព និងទៅតាមផ្នែកទាំង៥ ព្រមទាំងកំណត់គោលបំណងនៃដំណោះស្រាយនីមួយៗ ។

៤. លំហាត់ទី៣ "ការបំពេញតារាងជំនួយស្មារតីទី៣.១ និងទី៣.២" : អ្នកសំរបសំរួល ត្រូវបែងចែកសិក្ខាកាមជា៣ក្រុមស្មើៗគ្នា និងចែកសម្ភតិកម្មលំហាត់ (បញ្ជីដំណោះស្រាយនៃភូមិទាំង៦ក្នុងឃុំ) ដល់ក្រុមនីមួយៗ ។ បន្ទាប់មក ក្រុមនីមួយៗ :

- ស្រង់ដំណោះស្រាយនៃភូមិទាំង៦ចូលទៅក្នុងតារាងជំនួយស្មារតីទី៣.១ និងធ្វើការចាត់អាទិភាពដំណោះស្រាយទាំងនោះ ។
- បំពេញតារាងជំនួយស្មារតីទី៣.២ ដោយផ្អែកតាមលទ្ធផលតារាងជំនួយស្មារតីទី៣.១ ។

ក្រុមនីមួយៗ មិនចាំបាច់បង្ហាញលទ្ធផលនៃការពិភាក្សាទេ ដោយគ្រាន់តែបិទចំលើយទៅលើក្តារខៀនប៉ុណ្ណោះ ។

៥. អ្នកសំរបសំរួល បូកសរុបលទ្ធផលនៃក្រុមទាំង៣ ដោយពិនិត្យមើលចំលើយរួមគ្នាជាមួយសិក្ខាកាមទាំងអស់ ។ បន្ទាប់មក អ្នកសំរបសំរួល សួរទៅកាន់សិក្ខាកាម អំពីការលំបាកដែលពួកគេជួបប្រទះក្នុងពេលបំពេញតារាងទាំង២នេះ ហើយសូមអោយសិក្ខាកាមផ្តល់មតិយោបល់ ឬជំរើសនានា ក្នុងការបំពេញតារាងទាំង២នេះ ជាមួយ គ.ផ.ថ ។ រាល់មតិយោបល់ ឬជំរើសទាំងនេះ នៅលើក្រដាសផ្ទាំងធំ ។

## លំហាត់ទី៣ : ចូរបំពេញតារាងជំនួយស្មារតីទី៣.១ និងទី៣.២

១). ដំណោះស្រាយរបស់ភូមិ "ក"

| ប្រធានបទដែលត្រូវពិភាក្សា | | ដំណោះស្រាយដែលបានស្នើឡើងដោយអ្នកភូមិ | អាទិភាព | | |
|---|---|---|---|---|---|
| បញ្ហា | តំរូវការ | | ខ្ពស់ | មធ្យម | ទាប |
| | | ជីកអណ្តូងលូ | ✓ | | |
| | | សាងសង់មណ្ឌលសុខភាព | | ✓ | |
| | | បណ្តុះបណ្តាលឆ្មប | | | ✓ |
| | | ជួសជុលដំបូលសាលារៀន | | ✓ | |
| | | កម្មវិធីអប់រំក្រៅប្រព័ន្ធនៅភូមិ | | | ✓ |
| | | ជួសជុលទ្វារទឹក | | | ✓ |
| | | ពង្រីកប្រឡាយស្រោចស្រព | | | ✓ |
| | | ក្តារពតិមានភូមិ | | | ✓ |
| | | ពង្រឹងប្រជាការពារ | ✓ | | |
| | | សាងសង់សាលាឃុំ | | ✓ | |
| | | ផ្សព្វផ្សាយច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ | | ✓ | |
| | | ផ្សព្វផ្សាយអំពីសិទ្ធកុមារ | | | ✓ |
| | | ទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ | ✓ | | |
| | | ជំនួយដល់ការចិញ្ចឹមសត្វ | | ✓ | |
| | | ការដាំដើមឈើហូបផ្លែតាមគ្រួសារ | | ✓ | |
| | | ការបណ្តុះបណ្តាលអំពីការប្រើប្រាស់ជីកំប៉ុស្ត៍ | ✓ | | |
| | | ពេទ្យសត្វភូមិ | ✓ | | |
| | | កម្មវិធីចាក់វ៉ាក់សាំងសត្វ | ✓ | | |
| | | ផ្សព្វផ្សាយអំពីសារៈសំខាន់នៃព្រៃឈើ | | | ✓ |
| | | រុក្ខទិវា និងការដាំដើមឈើឡើងវិញ | | ✓ | |
| | | បង្កើតសហគមន៍ព្រៃឈើ | ✓ | | |

២). ដំណោះស្រាយរបស់ភូមិ "ខ"

| ប្រធានបទដែលត្រូវពិភាក្សា | | ដំណោះស្រាយដែលបានស្នើឡើងដោយអ្នកភូមិ | អាទិភាព | | |
|---|---|---|---|---|---|
| បញ្ហា | តំរូវការ | | ខ្ពស់ | មធ្យម | ទាប |
| | | ធនាគារសត្វគោ | ✓ | | |
| | | កម្មវិធីចាក់វ៉ាក់សាំងសត្វ | | | ✓ |
| | | បច្ចេកទេសធ្វើចង្ក្រានដែលសន្សំសំចៃអុស | | ✓ | |
| | | បណ្តុះបណ្តាលវិជ្ជាជីវៈ | ✓ | | |
| | | មណ្ឌលសុខភាព | ✓ | | |
| | | ភ្នាក់ងារសុខភាពភូមិ | | ✓ | |
| | | ស្តារស្រះទឹកភូមិ | | | ✓ |
| | | ជីកអណ្តូងស្នប់ | | ✓ | |
| | | ថ្នាក់អក្ខរកម្មសំរាប់ស្ត្រី | | ✓ | |
| | | ថ្នាក់មត្តេយ្យសាលា | | | ✓ |
| | | វុក្ខទិវា និងការដាំដើមឈើឡើងវិញ | | ✓ | |
| | | បង្កើតសហគមន៍ព្រៃឈើ | ✓ | | |
| | | បង្កើតតំបន់ទេសចរណ៍ធម្មជាតិ | | | ✓ |
| | | ពង្រឹងប្រជាការពារ | | ✓ | |
| | | ផ្សព្វផ្សាយ និងជំរុញការចុះអត្រានុកូលដ្ឋាន | ✓ | | |
| | | សាងសង់ស្នាក់ការភូមិ | | | ✓ |
| | | ផ្សព្វផ្សាយសិទ្ធិកុមារ | | ✓ | |
| | | ទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ | | | ✓ |
| | | ពង្រឹងជនបង្គោលស្ត្រី និងកុមារ | ✓ | | |

៣). ដំណោះស្រាយរបស់ភូមិ "គ"

| ប្រធានបទដែលត្រូវពិភាក្សា | | ដំណោះស្រាយដែលបានស្នើឡើង ដោយអ្នកភូមិ | អាទិភាព | | |
|---|---|---|---|---|---|
| បញ្ហា | តំរូវការ | | ខ្ពស់ | មធ្យម | ទាប |
| | | ជួសជុលទ្វារទឹក | ✓ | | |
| | | ស្ដារប្រឡាយទឹក | ✓ | | |
| | | ជួសជុលសាលារៀន | | ✓ | |
| | | បំពាក់សង្ហារឹម | | | ✓ |
| | | ក្ដារពតិមានភូមិ | | | ✓ |
| | | សាងសង់សាលាឃុំ | ✓ | | |
| | | ការផ្សព្វផ្សាយអំពីច្បាប់នានាដល់ប្រជាពលរដ្ឋ | | ✓ | |
| | | ឥណទានដែលមានអត្រាការប្រាក់ទាប | | | ✓ |
| | | បង្កន់អនាម័យតាមគ្រួសារ | | ✓ | |
| | | ជួសជុលផ្លូវភូមិ | ✓ | | |
| | | សាងសង់លូចកន្លែង | ✓ | | |
| | | ការផ្សព្វផ្សាយអំពើហិង្សាក្នុងគ្រួសារ | | ✓ | |
| | | ការផ្សព្វផ្សាយអំពីសិទ្ធិកុមារ | | | ✓ |
| | | ការផ្សព្វផ្សាយអំពីតួនាទីរបស់ស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍ | ✓ | | |
| | | ការផ្សព្វផ្សាយអំពីសារៈសំខាន់ព្រៃឈើ | | | ✓ |
| | | បង្កើតសហគមន៍ព្រៃឈើ | | ✓ | |
| | | ការផ្សព្វផ្សាយច្បាប់នានាដែលទាក់ទងនឹងធនធានធម្មជាតិ | ✓ | | |

៤). ដំណោះស្រាយរបស់ភូមិ "ឃ"

| ប្រធានបទដែលត្រូវពិភាក្សា | | ដំណោះស្រាយដែលបានស្នើឡើងដោយអ្នកភូមិ | អាទិភាព | | |
|---|---|---|---|---|---|
| បញ្ហា | តំរូវការ | | ខ្ពស់ | មធ្យម | ទាប |
| | | បណ្តុះបណ្តាលឆ្មបភូមិ | | | ✓ |
| | | មណ្ឌលសុខភាព | | ✓ | |
| | | ជួសជុលលូ១កន្លែង | ✓ | | |
| | | ជួសជុលស្ពាន១កន្លែង | ✓ | | |
| | | ទុនសំរាប់ប្រព័ន្ធឥណទាន | | | ✓ |
| | | ការបណ្តុះបណ្តាលអំពីការធ្វើនិងប្រើប្រាស់ជីកំប៉ុស្តិ៍ | | ✓ | |
| | | ការដាំឈើហូបផ្លែតាមគ្រួសារ | ✓ | | |
| | | សាងសង់អណ្តូងលូ | | ✓ | |
| | | ថ្នាក់អក្ខរកម្ម | | | ✓ |
| | | ថ្នាក់មត្តេយ្យសាលា | | | ✓ |
| | | ការផ្សព្វផ្សាយអំពីសារៈសំខាន់ព្រៃឈើ | | ✓ | |
| | | បង្កើតសហគមន៍នេសាទ | ✓ | | |
| | | ពង្រឹងប្រជាការពារ | | | ✓ |
| | | ផ្សព្វផ្សាយ និងជំរុញការចុះអត្រានុកូលដ្ឋាន | | ✓ | |
| | | ផ្សព្វផ្សាយអំពីច្បាប់នានាដល់ប្រជាពលរដ្ឋ | ✓ | | |
| | | ទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ | | ✓ | |
| | | ពង្រឹងជនបង្គោលស្ត្រី និងកុមារ | ✓ | | |
| | | ផ្សព្វផ្សាយអំពីតួនាទីស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍ | | | ✓ |

## ៥). ដំណោះស្រាយរបស់ភូមិ "ង"

| ប្រធានបទដែលត្រូវពិភាក្សា | | ដំណោះស្រាយដែលបានស្នើឡើង ដោយអ្នកភូមិ | អាទិភាព | | |
|---|---|---|---|---|---|
| បញ្ហា | តំរូវការ | | ខ្ពស់ | មធ្យម | ទាប |
| | | ក្រាលក្រួសក្រហម | ✓ | | |
| | | ដាក់លូ | ✓ | | |
| | | ជួសជុលស្ពាន | ✓ | | |
| | | ការដាំដំណាំឈើហូបផ្លែតាមគ្រួសារ | | | ✓ |
| | | សួនបន្លែតាមផ្ទះ | | ✓ | |
| | | ជួសជុលទ្វារទឹក | | | ✓ |
| | | ពង្រីកប្រឡាយស្រោចស្រព | | | ✓ |
| | | សាងសង់ប្រព័ន្ធអគ្គិសនី | | | ✓ |
| | | ផ្សព្វផ្សាយអំពើហឹង្សាក្នុងគ្រួសារ | | ✓ | |
| | | ទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ | | | ✓ |
| | | ផ្សព្វផ្សាយអំពីតួនាទីស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍ | ✓ | | |
| | | ការបណ្តុះបណ្តាលកសិកម្ម | ✓ | | |
| | | ថ្នាក់អក្ខរកម្មសំរាប់ស្ត្រី | | ✓ | |
| | | ថ្នាក់មត្តេយ្យសាលា | | ✓ | |
| | | រុក្ខទិវា និងការដាំដើមឈើឡើងវិញ | | ✓ | |
| | | ការផ្សព្វផ្សាយច្បាប់នានាដែលទាក់ទងនឹងធនធានធម្មជាតិ | | | ✓ |
| | | បង្កើតថ្នាលបណ្តុះកូនឈើភូមិ | ✓ | | |
| | | សាងសង់សាលាឃុំ | | | ✓ |
| | | ផ្សព្វផ្សាយ និងជំរុញការចុះអត្រានុកូលដ្ឋាន | ✓ | | |
| | | ផ្សព្វផ្សាយច្បាប់នានាដល់ប្រជាពលរដ្ឋ | | ✓ | |

៦). ដំណោះស្រាយរបស់ភូមិ "ច"

| ប្រធានបទដែលត្រូវពិភាក្សា | | ដំណោះស្រាយដែលបានស្នើឡើងដោយអ្នកភូមិ | អាទិភាព | | |
|---|---|---|---|---|---|
| បញ្ហា | តំរូវការ | | ខ្ពស់ | មធ្យម | ទាប |
| | | ផលទាននអត្រាការប្រាក់ទាប | | ✓ | |
| | | ជួសជុលផ្លូវទៅឃុំ | | ✓ | |
| | | សាងសង់ស្ពានថ្មី | | ✓ | |
| | | ជួសជុលថ្នាក់រៀន | | | ✓ |
| | | បំពាក់សង្ហារឹម | | | ✓ |
| | | ក្តារពត៌មានភូមិ | | | ✓ |
| | | ពង្រឹងប្រជាការពារ | | ✓ | |
| | | សាងសង់ស្នាក់ការភូមិ | ✓ | | |
| | | ផ្សព្វផ្សាយច្បាប់នានាដល់ប្រជាពលរដ្ឋ | ✓ | | |
| | | ការផ្សព្វផ្សាយអំពីសិទ្ធិកុមារ | | ✓ | |
| | | ការផ្សព្វផ្សាយអំពីអំពើហិង្សាក្នុងគ្រួសារ | | | ✓ |
| | | ពង្រឹងជនបង្គោលស្ត្រី និងកុមារ | ✓ | | |
| | | ការផ្សព្វផ្សាយអំពីសារៈសំខាន់នៃព្រៃឈើ | ✓ | | |
| | | បង្កើតសហគមន៍ព្រៃឈើ | | ✓ | |
| | | បង្កើតតំបន់ទេសចរណ៍ធម្មជាតិ | | | ✓ |
| | | សាងសង់បង្គន់នៅតាមគ្រួសារ | ✓ | | |

## តារាងជំនួយស្មារតីទី៣.១

| ល.រ | ដំណោះស្រាយ | [illegible] | | | | | | [illegible] | | | អាទិភាព |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ក | ខ | គ | ឃ | ង | ច | ធនធានឃុំ | ភាពចាំបាច់ | សរុប | |
| សេដ្ឋកិច្ច | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| សង្គមកិច្ច | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| ធនធានធម្មជាតិ និងបរិស្ថាន | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| សេវាកម្មរដ្ឋបាល និងសន្តិសុខ | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| យេនឌ័រ | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

## តារាងជំនួយស្មារតីទី៣.២

| លរ | ដំណោះស្រាយឃុំ សង្កាត់ | អាទិភាព | ក្នុងគោលបំណង | យោបល់ឯកភាព របស់ជនជាតិដើមភាគតិច |
|---|---|---|---|---|
| សេដ្ឋកិច្ច | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| សង្គមកិច្ច | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| ធនធានធម្មជាតិ និងបរិស្ថាន | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| សេវាកម្មរដ្ឋបាល និងសន្តិសុខ | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| យេនឌ័រ | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួនដែលអាចជាជួយដល់អ្នកសំរបសំរួល ក្នុងការបញ្ចូលដំណោះស្រាយ ទៅតាមផ្នែកទាំង៥ :

| |
|---|
| សេដ្ឋកិច្ច |
| កសិកម្ម : ក្សេត្រសាស្ត្រ និងកែលំអដី |
| កសិកម្ម : ផលិតកម្ម និងបសុព្យាបាល |
| កសិកម្ម : ជលផល |
| កសិកម្ម : ផ្សព្វផ្សាយកសិកម្ម |
| ធារាសាស្ត្រ : ប្រឡាយ ទំនប់ ទ្វារទឹក អាងស្តុកទឹក ម៉ាស៊ីនបូមទឹក |
| ធារាសាស្ត្រ : ក្រុមប្រើប្រាស់ទឹក |
| ឥណទាន : សំណង់សំរាប់ឥណទាន |
| ឥណទាន : ការបង្កើតក្រុម និងបណ្តុះ បណ្តាល |
| ឥណទាន : ទុន |
| ហេដ្ឋារចនាសម្ព័ន្ធ : ផ្លូវលំ (លូ ស្ពាន ក្រាលគ្រួសក្រហម ផ្លូវដីស ។ល។) |
| ហេដ្ឋារចនាសម្ព័ន្ធ : ការសាងសង់ផ្សារ និងការជួសជុល |
| ហេដ្ឋារចនាសម្ព័ន្ធ : ប្រព័ន្ធអគ្គិសនី |
| សង្គមកិច្ច |
| សុខាភិបាល : មណ្ឌល ឬ ប៉ុស្តិ៍សុខភាព |
| សុខាភិបាល : ការអប់រំផ្សព្វ ផ្សាយ ការបណ្តុះបណ្តាល និងយុទ្ធនាការ |
| សេវាសុខាភិបាល : ឆ្មប ភ្នាក់ងារសុខភាព |
| សុខាភិបាល : ឱសថបូរាណ |
| អប់រំ : ការសាងសង់និងជួសជុល សាលារៀន សាងសង់បង្គន់នៅក្នុងសាលារៀន |
| អប់រំ : អប់រំក្រៅប្រព័ន្ធ |
| អប់រំ : ការបណ្តុះបណ្តាល វិជ្ជាជីវៈ |
| អប់រំ : មត្តេយ្យសាលា |
| អប់រំ : គ្រូបង្រៀន (បឋម ឬមធ្យម សិក្សាបឋមភូមិ) |
| អនាម័យ និងទឹកស្អាត : អណ្តូង ស្រះ អាងទឹកខ្នាតតូច |
| អនាម័យ និងទឹកស្អាត : ប្រព័ន្ធទឹកស្អាត |

| |
|---|
| អនាម័យ និងទឹកស្អាត : បង្គន់ |
| អនាម័យ និងទឹកស្អាត : ក្រុមប្រើប្រាស់ |
| អនាម័យនិងទឹកស្អាត : ការបណ្តុះបណ្តាល |
| អនាម័យ និងទឹកស្អាត : ប្រឡាយបង្ហូរទឹក |
| កិច្ចការសង្គម : ការបង្កើតគណៈ កម្មការ ឬសហគមន៍ និងការបណ្តុះបណ្តាល |
| កិច្ចការសង្គម : សិទ្ធិមនុស្ស |
| **ធនធានធម្មជាតិ និងបរិស្ថាន** |
| សហគមន៍ព្រៃឈើ ថ្នាលបណ្តុះ កូនឈើ ការដាំដើមឈើ |
| ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន |
| ទេសចរណ៍បរិស្ថាន ទីកន្លែងវប្បធម៌ |
| សត្វព្រៃ |
| ការគ្រប់គ្រងដីធ្លី |
| **សេវាកម្មរដ្ឋបាល និងសន្តិសុខ** |
| សាលាឃុំ ស្នាក់ការភូមិ និង សំភារៈ (រួមទាំងមធ្យោបាយ ធ្វើដំណើរ ទំនាក់ទំនង) |
| សេវាកម្ម បុគ្គលិក ការផ្សព្វផ្សាយ និងការបណ្តុះបណ្តាល |
| សកម្មភាព/អន្តរាគមន៍សន្តិសុខ |
| **យេនឌ័រ** |
| អំពើហិង្សាក្នុងគ្រួសារ |
| ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយអំពីយេនឌ័រ |
| សិទ្ធិកុមារ និងការជួញដូរស្ត្រី និងកុមារ |

# ប្លង់មេរៀនជំហានទី៤
## ការកំណត់ទិសដៅ និងយុទ្ធសាស្ត្រវិនិយោគ



គោលបំណង : សិក្ខាកាម យល់ដឹងច្បាស់អំពីរបៀបគាំទ្រដល់ឃុំ សង្កាត់ ក្នុងការកំណត់ទិសដៅនិងយុទ្ធសាស្ត្រវិនិយោគ និងសកម្មភាពសំរាប់រយៈពេល៣ឆ្នាំ ។



រយៈពេល : ប្រហែល២ម៉ោង



សំភារៈចាំបាច់ : ក្រដាសផ្ទាំងធំសំរាប់ឡើងបង្ហាញ (ព្រីនចេញពីកំព្យូទ័រ) ក្រដាសផ្ទាំងធំសំរាប់សរសេរ ស្កត់ និងហ្វឺត ។

វិធីសាស្ត្រ : ការបំផុសគំនិត ការបង្ហាញ ក្រុមពិភាក្សា និងការបូកសរុប ។



កំណត់ចំណាំសំរាប់គ្រូឧទ្ទេស : នៅជំហាននេះ មិនត្រូវអោយធ្វើការសរសេរឡើងវិញ នូវចក្ខុវិស័យ ទិសដៅ និងយុទ្ធសាស្ត្រនៃផែនការអភិវឌ្ឍន៍៥ឆ្នាំទេ គឺរៀបចំតែទិសដៅនិងយុទ្ធសាស្ត្រវិនិយោគ និងសកម្មភាពសំរាប់ការវិនិយោគរយៈពេល៣ឆ្នាំប៉ុណ្ណោះ ។

អ្នកសំរបសំរួល ត្រូវបញ្ជាក់ដល់មេឃុំ ចៅសង្កាត់ផងដែរថា ជនបង្គោលទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ នឹងចូលរួមក្នុងការពិភាក្សានៅជំហាននេះ ។

របៀបសំរបសំរួលមេរៀន :



១. អ្នកសំរបសំរួល ចាប់ផ្តើមដោយបញ្ជាក់ថា "ឃុំ សង្កាត់ បានរៀបចំចក្ខុវិស័យ ទិសដៅ យុទ្ធសាស្ត្រ និងសកម្មភាពអភិវឌ្ឍន៍របស់ខ្លួនសំរាប់រយៈពេល៥ឆ្នាំ កាលពីឆ្នាំកន្លងមករួចមកហើយ ។ នៅពេលនេះ ឃុំ សង្កាត់ នឹងរៀបចំទិសដៅបន្ទាន់ សំរាប់រយៈពេល៣ឆ្នាំ និងរៀបចំយុទ្ធសាស្ត្រនានា ដោយផ្អែកតាមទិសដៅបន្ទាន់ ។ ផ្អែកតាមយុទ្ធសាស្ត្រទាំងនេះ ឃុំ សង្កាត់ នឹងរៀបចំសកម្មភាពសំរាប់រយៈពេល៣ឆ្នាំ" ។

២. មុនចូលដល់ការពន្យល់អំពីទិសដៅ អ្នកសំរបសំរួល ត្រូវបំផុសសំណួរ "តើចក្ខុវិស័យមានន័យយ៉ាងដូចម្តេច?" ។ ចំលើយឬយោបល់របស់សិក្ខាកាម ត្រូវកត់ត្រានៅលើក្រដាសផ្ទាំងធំ ។ បន្ទាប់មក អ្នកសំរបសំរួល ត្រូវបូកសរុបចំលើយទាំងនោះ ដោយបង្ហាញនិយមន័យនៃពាក្យចក្ខុវិស័យ និងលើកឡើងនូវឧទាហរណ៍ ។

នៅថ្នាក់ឃុំ សង្កាត់ : ដើម្បីអោយ គ.ជ.ថ កាន់តែងាយស្រួលក្នុងការយល់ដឹងអំពីចក្ខុវិស័យ អ្នកសំរបសំរួល អាចយកឃ្លាចក្ខុវិស័យរបស់ឃុំ សង្កាត់នោះ មកពិនិត្យមើល ហើយសូមអោយ គ.ជ.ថ ផ្តល់យោបល់ផ្សេងៗ ។

ចក្ខុវិស័យ គឺជាការប្រមើមើលស្ថានភាពអនាគតវែងឆ្ងាយ ដែលគេប្រាថ្នាចង់បាន ដោយសំដៅសំខាន់ទៅលើគុណភាពនៃជីវិត ។ ការសរសេរចក្ខុវិស័យ ត្រូវតែជាឃ្លាប្រយោគវិជ្ជមាន ។

ឧទាហរណ៍ : គ្រប់គ្រងឃុំ សង្កាត់តាមបែបប្រជាធិបតេយ្យដោយមានការចូលរួម ពីប្រជាពលរដ្ឋ សង្គមស៊ីវិល ផ្នែកឯកជន និងរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន ។ ក្រុមប្រឹក្សាឃុំ សង្កាត់ គ្រប់គ្រងការអភិវឌ្ឍន៍ប្រកបដោយតម្លាភាព សមភាព និងប្រសិទ្ធភាព ដើម្បីសន្តិភាព និងយុត្តិធម៌ ព្រមទាំងធ្វើអោយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋបានប្រសើរឡើងជានិរន្តន៍ ។

៣. ទិសដៅបន្ទាន់ : អ្នកសំរបសំរួល ចាប់ផ្តើមដោយលើកឡើងនូវសំណួរ "តើទិសដៅអភិវឌ្ឍន៍ និងទិសដៅបន្ទាន់សំរាប់រយៈពេលវិនិយោគ៣ឆ្នាំខុសគ្នាយ៉ាងដូចម្តេច?" ។ កត់ត្រាចំលើយ និងយោបល់ផ្សេងៗ នៅលើក្រដាសផ្ទាំងធំ ។

ទិសដៅ គឺជាផលរំពឹងទុកដែលត្រូវសំរេចអោយបានក្នុងរយៈពេលមួយកំណត់ ដើម្បីឆ្ពោះទៅរកចក្ខុវិស័យដែលបានលើកឡើង ។

ទិសដៅបន្ទាន់ គឺជាបំណងប្រាថ្នាដែលសង្ឃឹមថានឹងទទួលបាននៅក្រោយពីការអនុវត្តគំរោងវិនិយោគ ។

ឃ្លាទិសដៅបន្ទាន់ គឺជាឃ្លាមួយមានភាពជាក់លាក់ ដែលបញ្ជាក់នូវពេលវេលា និងកំរិតដែលអាចសំរេចបាននៅក្នុងរយៈពេលនោះ ។ ទិសដៅបន្ទាន់ អាចមានលើសពីចំនួន១នៅក្នុងផ្នែកនីមួយៗ ។

៤. យុទ្ធសាស្ត្រ : អ្នកសំរបសំរួល បន្តដោយសំដុសសំណួរថា "តើយុទ្ធសាស្ត្រមានន័យយ៉ាងដូចម្តេច?" ។ កត់ត្រាចំលើយ និងយោបល់ផ្សេងៗ នៅលើក្រដាសផ្ទាំងធំ ។ បន្ទាប់មកអ្នកសំរបសំរួល ត្រូវបូកសរុប និងបង្ហាញនិយមន័យនៃពាក្យយុទ្ធសាស្ត្រ ។

យុទ្ធសាស្ត្រ គឺជាវិធី ឬជំរើសដែលឃុំ សង្កាត់ត្រូវប្រកាន់យកដើម្បីសំរេចទិសដៅប្រកបដោយប្រសិទ្ធភាពបំផុត ។ សំរាប់កម្មវិធីវិនិយោគឃុំ សង្កាត់ យុទ្ធសាស្ត្រ គឺជាចង្កោមសកម្មភាពនានាដែលត្រូវអនុវត្ត ដើម្បីសំរេចនូវទិសដៅបន្ទាន់ ។

៥. អ្នកសំរបសំរួល បង្ហាញ និងពន្យល់តារាងជំនួយស្មារតីទី៤ ។ តារាងជំនួយស្មារតីទី៤នេះ មិនមែនជាតារាងថ្មីទេ ដោយគ្រាន់តែបញ្ចូលពត៌មានទៅតាមក្រុមរបស់វា នៅក្នុងទំរង់រួមមួយប៉ុណ្ណោះ ។ នៅក្នុងទំរង់រួមនេះ ទិសដៅបន្ទាន់ យុទ្ធសាស្ត្រ និងសកម្មភាព ត្រូវបានដាក់លេខរៀង ដោយមានទំនាក់ទំនងគ្នា ។

៦. លំហាត់ទី៤ : ចូរពិភាក្សា និងបង្កើតទិសដៅបន្ទាន់ យុទ្ធសាស្ត្រ និងសកម្មភាពសំរាប់រយៈពេល៣ឆ្នាំ ដោយផ្អែកតាមពត៌មានដែលបានផ្តល់ជូន ។ អ្នកសំរបសំរួល ចែកសិក្ខាកាមជា៥ក្រុម :

- ក្រុមទី១ ផ្តោតទៅលើផ្នែក "សេដ្ឋកិច្ច និង ធនធានធម្មជាតិនិងបរិស្ថាន" ។
- ក្រុមទី២ ផ្តោតទៅលើផ្នែក "សង្គមកិច្ច និង យេនឌ័រ" ។
- ក្រុមទី៣ ផ្តោតទៅលើផ្នែក "សេវាកម្មរដ្ឋបាលនិងសន្តិសុខ និង សេដ្ឋកិច្ច" ។
- ក្រុមទី៤ ផ្តោតទៅលើផ្នែក "ធនធានធម្មជាតិនិងបរិស្ថាន និង សង្គមកិច្ច" ។
- ក្រុមទី៥ ផ្តោតទៅលើផ្នែក "យេនឌ័រ និង សេវាកម្មរដ្ឋបាលនិងសន្តិសុខ" ។

ក្រុមនីមួយៗ បង្ហាញលទ្ធផលរបស់ក្រុមខ្លួន និងសំណួរចំលើយ ។ បន្ទាប់មក អ្នកសំរបសំរួល ធ្វើការបូកសរុប ។

## តារាងជំនួយស្មារតីទី៤

| ទិសដៅ (សេដ្ឋកិច្ច) : | |
|---|---|
| **យុទ្ធសាស្ត្រ** | **សកម្មភាព** |
| | |
| | |
| **ទិសដៅ (សង្គមកិច្ច) :** | |
| **យុទ្ធសាស្ត្រ** | **សកម្មភាព** |
| | |
| | |
| **ទិសដៅ (ធនធានធម្មជាតិនិងបរិស្ថាន) :** | |
| **យុទ្ធសាស្ត្រ** | **សកម្មភាព** |
| | |
| | |

ទិសដៅ ( សេវាកម្មរដ្ឋបាល និងសន្តិសុខ) :

| យុទ្ធសាស្ត្រ | សកម្មភាព |
|---|---|
| | |
| | |

ទិសដៅ ( យេនឌ័រ) :

| យុទ្ធសាស្ត្រ | សកម្មភាព |
|---|---|
| | |
| | |

# ប្លង់មេរៀនជំហានទី៥
# ការកំណត់គំរោងដែលត្រូវវិនិយោគ

គោលបំណង : សិក្ខាកាម យល់ដឹងអំពីរបៀបរៀបចំគំរោងវិនិយោគ និងវិធីសាស្ត្រសំរបសំរួលជាមួយ គ.ជ.ថ ដើម្បីបំពេញតារាងជំនួយស្មារតីទី៥ ។



រយៈពេល : ប្រហែល២ម៉ោង



សំភារៈចាំបាច់ : លទ្ធផលនៃជំហានទី២ (តារាងទី២) ទី៣ (តារាងទី៣.២) និងទី៤ (តារាងទី៤) និងតារាងជំនួយស្មារតីទី៥ដែលមិនទាន់បានបំពេញ ក្រដាសផ្ទាំងធំ ហ្វឺត និងស្កត់ ។

វិធីសាស្ត្រ : ការបង្ហាញ ក្រុមពិភាក្សាដើម្បីធ្វើលំហាត់ និងបូកសរុប ។



កំណត់ចំណាំសំរាប់គ្រូឧទ្ទេស : នៅជំហានទី៥នេះ អ្នកសំរបសំរួល នឹងប្រើប្រាស់បញ្ជីគំរោងវិនិយោគឆ្នាំកន្លងទៅ (តារាងទី៧ចាស់) ដើម្បីផ្ទៀងផ្ទាត់ជាមួយតារាងជំនួយស្មារតីទី៥ ។ អ្នកសំរបសំរួល ត្រូវបញ្ជាក់ដល់មេឃុំ ចៅសង្កាត់ផងដែរថា ជនបង្គោលទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ នឹងចូលរួមក្នុងការពិភាក្សានៅជំហាននេះ ។

របៀបសំរបសំរួលមេរៀន :



១. អ្នកសំរបសំរួល ត្រូវចាប់ផ្តើមដោយរំលឹកសិក្ខាកាមយ៉ាងខ្លី អំពីរបៀបដែលពួកគេបានរៀបចំបញ្ជីសកម្មភាពនៅជំហានទី៤ ហើយបញ្ជាក់ដល់សិក្ខាកាមថា សកម្មភាពដែលបានកំណត់ទាំងអស់ នឹងរៀបចំអោយទៅជាគំរោង ។

២. អ្នកសំរបសំរួល បង្ហាញ និងពន្យល់ អំពី :

- គំរោង : តើគំរោងគឺជាអ្វី? តើគំរោងបែបណាខ្លះដែលអាច បញ្ចូលជាមួយគ្នាបាន? តើគំរោងបែបណាខ្លះដែលមិនអាចបញ្ចូលគ្នាបាន?
- លទ្ធផល អ្នកទទួលផល និងប្រភេទគំរោង ។

## ក). គំរោង និងលទ្ធផល

គំរោងឃុំ សង្កាត់ មានលក្ខណៈជាសំណុំនៃលទ្ធផល ដែលរួមគ្នាដើម្បីសំរេចទិសដៅមួយ ។ លទ្ធផលគឺជាអ្វីមួយដែលបានបង្កើតឡើងដោយគំរោង ហើយដែលយើងអាចរាប់ ឬវាស់វែងបាន ។ គំរោងមួយអាចមាន :

- ➢ លទ្ធផលខុសៗគ្នា នៅទីតាំងតែមួយ (ឧទាហរណ៍ : ទំនប់មួយខ្សែ ទ្វារទឹកមួយកន្លែង និងប្រឡាយមួយខ្សែ បង្កើតបានជាគំរោងមួយហៅថាគំរោងប្រព័ន្ធធារាសាស្ត្រ) ។
- ➢ លទ្ធផលជាច្រើនដូចៗគ្នា នៅទីតាំងផ្សេងគ្នា (ឧទាហរណ៍ : អណ្តូង នៅ៥ភូមិ) ។

គំរោងមួយ ត្រូវមាន :

- ឈ្មោះមួយ ។ ជាការសំខាន់ ក្នុងការផ្តល់ឈ្មោះមួយអោយគំរោង ដើម្បីញែកវាអោយដាច់ពីគំរោងផ្សេងទៀត ។
- ប្រភេទគំរោង (ឧទាហរណ៍ : "ផ្គត់ផ្គង់ទឹកស្អាតជនបទ" "គមនាគមន៍ជនបទ")
- រយៈពេល និងគំរោងថវិកា (គំរោងថវិកា ដកស្រង់ចេញពីកម្មវិធីវិនិយោគឃុំ សង្កាត់)
- យ៉ាងហោចណាស់មានទីតាំងមួយ ។ ជាធម្មតា ទីតាំង ជាភូមិមួយ ឬភូមិច្រើនជាងមួយ ។
- យ៉ាងហោចណាស់មានលទ្ធផលមួយ ។

លទ្ធផលមួយ ត្រូវមាន :

- ប្រភេទលទ្ធផលមួយ
- ទីតាំងមួយ ។ ចំពោះ គំរោងឃុំ សង្កាត់ លទ្ធផលមួយ ត្រូវបានកំណត់ថា ជាទីតាំងនៅភូមិមួយ ។ ប្រសិនបើ គំរោងមួយមានសកម្មភាពដូចគ្នានៅ២ភូមិ យើងរាប់២លទ្ធផល ។
- ឯកតាមួយសំរាប់ការវាស់វែង ។
- បរិមាណមួយ ។

កំណត់សំគាល់ :

- គំរោងជាច្រើន អាចមានប្រភេទគំរោងតែមួយ ។ ប្រសិនបើ លទ្ធផល នៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ គឺជាផ្លូវក្រាលគ្រួសក្រហម ហើយលទ្ធផលមួយផ្សេងទៀត គឺជាអណ្តូងស្នប់ ។ លទ្ធផលទាំងនេះ ត្រូវតែដាក់ នៅក្នុងគំរោង២ផ្សេងគ្នា : "គំរោងផ្គត់ផ្គង់ទឹកស្អាតជនបទ" និង "គំរោងផ្លូវលំជនបទ" ។
- លទ្ធផលនានាដែលរួមគ្នាដើម្បីសំរេចទិសដៅតែមួយ ត្រូវដាក់ជាមួយគ្នានៅក្នុងគំរោងមួយ ។ ជាឧទាហរណ៍ : លូ ស្ពាន និងក្រាលគ្រួសក្រហម នៅលើផ្លូវមួយខ្សែ ត្រូវដាក់ជាមួយគ្នានៅក្នុងគំរោងមួយ ។

ឧទាហរណ៍ អំពីគំរោង និងលទ្ធផល :

| ប្រភេទគំរោង | លទ្ធផល |
|---|---|
| គមនាគមន៍ក្នុងតំបន់ជនបទ | ដាក់លូ៨កន្លែង សាងសង់ស្ពាន១កន្លែង និងក្រាលគ្រួសក្រហមប្រវែង៣គម សំរាប់ ផ្លូវមួយខ្សែឆ្លងកាត់៣ភូមិ ។ |
| ផ្គត់ផ្គង់ទឹកស្អាត | អណ្តូងលូចំនួន៨ នៅក្នុងភូមិ៣ និងអណ្តូងស្នប់ចំនួន១២ នៅក្នុងភូមិ៤ ។ |
| ការអប់រំ | សាងសង់សាលារៀន២បន្ទប់ បំពាក់សង្ហារឹម អណ្តូងមួយ និងបង្គន់អនាម័យ ចំនួន២ នៅសាលារៀនមួយ ។ |
| ការអប់រំសំរាប់មនុស្សពេញវ័យ | ថ្នាក់អក្ខរកម្ម នៅ៣ភូមិ ។ |
| អន្តរាគមន៍ផ្នែកសង្គមកិច្ច | ផ្សព្វផ្សាយដើម្បីកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ ។ |

## ខ). អ្នកទទួលផល និងប្រភេទគំរោង

អ្នកទទួលផលដែលត្រូវបំពេញនៅក្នុងកូឡោនទី៩នៃតារាងទី៥ គឺជាអ្នកទទួលផលដោយផ្ទាល់ពីលទ្ធផលគំរោង ។ អ្នកទទួលផលផ្ទាល់ពីគំរោង គឺជាប្រជាពលរដ្ឋ និងក្រុមគ្រួសារដែលប្រើប្រាស់សមិទ្ធិផលគំរោងដោយផ្ទាល់ ។ ឯកតានៃអ្នកទទួលផលផ្ទាល់ គឺជា "នាក់" ។ ឧទាហរណ៍ :

- អ្នកទទួលផលប្រយោជន៍ដោយផ្ទាល់ពីអណ្តូងទឹក គឺជាសមាជិកទាំងអស់ នៅក្នុងគ្រួសារដែលប្រើប្រាស់ទឹកអណ្តូង មិនមែនគ្រាន់តែជាអ្នកដែលទៅដងទឹកអណ្តូងនោះប៉ុណ្ណោះទេ ។
- អ្នកទទួលផលដោយផ្ទាល់ពីសាលារៀន គឺសមាជិកទាំងអស់ នៅក្នុងគ្រួសារដែលបានបញ្ជូនកូនទៅសាលារៀន មិនមែនតែកុមារដែលទៅសាលារៀនប៉ុណ្ណោះនោះទេ ។

តារាងខាងក្រោមនេះ គឺជាប្រភេទគំរោង និងអ្នកទទួលផលគំរោងមួយចំនួន :

| លរ | ប្រភេទគំរោង | ឧទាហរណ៍លទ្ធផលគំរោង | អ្នកទទួលផល |
|---|---|---|---|
| ១ | គមនាគមន៍ក្នុងតំបន់ជនបទ | ផ្លូវលំ លូ ស្ពាន ទូកចំលង សាឡាង ។ល។ | គ្រប់គ្រួសារនៅក្នុងភូមិទាំងអស់ ។ |
| ២ | គមនាគមន៍ក្នុងតំបន់ទីក្រុង | ផ្លូវថ្នល់ ចំណតរថយន្ត | គ្រប់គ្រួសារនៅក្នុងភូមិទាំងអស់ ។ |
| ៣ | កសិកម្ម | ធនាគារសត្វគោ ធនាគារស្រូវ ការបណ្តុះបណ្តាលកសិកម្ម ។ល។ | គ្រួសារដែលទទួលផលផ្ទាល់ពីសកម្មភាពទាំងនេះ ។ |
| ៤ | ធារាសាស្ត្រ | ទំនប់ ប្រឡាយ ទ្វារទឹក ស្ថានីយ៍បូមទឹក ម៉ាស៊ីនបូមទឹក ក្រុមកសិករប្រើប្រាស់ទឹក ។ល។ | គ្រួសារដែលដីស្រែរបស់ខ្លួន ទទួលបាននូវការស្រោចស្រព ។ |
| ៥ | ហេដ្ឋារចនាសម្ព័ន្ធទីផ្សារ | សំណង់ផ្សារ ប្រព័ន្ធទឹកស្អាត និងអនាម័យនៅទីផ្សារ ។ល។ | គ្រប់គ្រួសារទាំងអស់នៅក្នុងភូមិ ដែលប្រើប្រាស់ផ្សារនេះ ។ |
| ៦ | អគ្គិសនី | ប្រព័ន្ធចែកចាយអគ្គិសនី ម៉ាស៊ីនភ្លើង ។ល។ | គ្រួសារដែលប្រើប្រាស់ភ្លើងអគ្គិសនី ។ |
| ៧ | អភិវឌ្ឍន៍ផ្នែកសិប្បកម្ម | ការបណ្តុះបណ្តាលសំរាប់ជំនួញ (ការរកស៊ី) ។ល។ | គ្រួសារដែលជីវភាពរស់នៅរបស់ពួកគេទទួលបានការគាំទ្រដោយសិប្បកម្ម ។ |
| ៨ | ឥណទាននិងការសន្សំប្រាក់ | ការបណ្តុះបណ្តាលក្រុមឥណទាន ការបង្កើតក្រុមឥណទាន និងក្រុមសន្សំប្រាក់ ។ល។ | គ្រួសារដែលជាសមាជិកក្រុមឥណទាន ឬក្រុមសន្សំប្រាក់ ។ |

| លរ | ប្រភេទគំរោង | ឧទាហរណ៍លទ្ធផលគំរោង | អ្នកទទួលផល |
|---|---|---|---|
| ៩ | អភិវឌ្ឍន៍ផ្នែកទេសចរណ៍ | មណ្ឌលទេសចរណ៍ ប្រព័ន្ធទឹកស្អាតនិងអនាម័យនៅកន្លែងទេសចរណ៍ ការបណ្តុះបណ្តាលមគ្គុទ្ទេសទេសចរណ៍ ។ល។ | គ្រួសារដែលទទួលផលពីកន្លែងទេសចរណ៍ ។ |
| ១០ | ប្រពន្ធ័បង្ហូរទឹកស្អុយជនបទ | ប្រឡាយឬលូបង្ហូរទឹក | គ្រប់គ្រួសារទាំងអស់នៅក្នុងភូមិ ។ |
| ១១ | ប្រពន្ធ័បង្ហូរទឹកស្អុយទីក្រុង | ប្រឡាយឬលូបង្ហូរទឹក ប្រព័ន្ធចម្រោះទឹកស្អុយអោយទៅជាទឹកស្អាត | គ្រប់គ្រួសារទាំងអស់នៅក្នុងភូមិ ។ |
| ១២ | ផ្គត់ផ្គង់ទឹកស្អាតជនបទ | អណ្តូង ស្រះ ប្រព័ន្ធទឹកស្អាត ប្រព័ន្ធចម្រោះទឹក ។ល។ | គ្រួសារដែលប្រើប្រាស់លទ្ធផលទាំងនេះ |
| ១៣ | ផ្គត់ផ្គង់ទឹកស្អាតទីក្រុង | អណ្តូង ប្រព័ន្ធទឹកស្អាត ។ល។ | គ្រួសារដែលប្រើប្រាស់លទ្ធផលទាំងនេះ |
| ១៤ | ប្រមូលសំរាម ឬកាកសំណល់ | សេវាកម្មប្រមូល និងដឹកសំរាម | គ្រួសារដែលបានទទួលសេវាកម្មនេះ ។ |
| ១៥ | អប់រំ (ចំណេះទូទៅ) | សងសាលារៀន ប្រព័ន្ធទឹកស្អាត និងអនាម័យសំរាប់សាលារៀន សំភារៈបរិក្ខារ ឯកសារបណ្តុះបណ្តាល បង្គន់អនាម័យ ។ល។ | គ្រួសារដែលមានកូនចៅរៀននៅសាលានោះ ។ |
| ១៦ | អប់រំមនុស្សពេញវ័យ | ថ្នាក់អក្ខរកម្ម និងសេវាកម្មអប់រំមនុស្សពេញវ័យដទៃទៀត ។ | គ្រួសារដែលបានចូលរៀន ។ |
| ១៧ | សុខាភិបាល | មណ្ឌល ឬប៉ុស្តិ៍សុខភាព សំភារៈបរិក្ខារសំរាប់មណ្ឌល ឬប៉ុស្តិ៍សុខភាព ឡានពេទ្យ សកម្មភាពអប់រំសុខភាព និងសេវាសុខភាពនានា | គ្រួសារដែលទទួលបាននូវសេវាកម្មទាំងនោះ ។ |
| ១៨ | វប្បធម៌ និងសាសនា | ឧបករណ៍ភ្លេង ក្រុមតន្ត្រីឬសិល្បៈល្ខោនបាសាក់ អាយ៉ៃ យីកេ ។ល។ | គ្រួសារដែលជាសមាជិកក្រុមទាំងនោះ |
| ១៩ | គ្រប់គ្រងធនធានធម្មជាតិ | សហគមន៍ព្រៃឈើ សហគមន៍នេសាទ ការផ្សព្វផ្សាយនិងការ | គ្រួសារដែលជាសមាជិកសហគមន៍ ។ |

| លរ | ប្រភេទគំរោង | ឧទាហរណ៍លទ្ធផលគំរោង | អ្នកទទួលផល |
|---|---|---|---|
| | | បណ្តុះបណ្តាលនានាដែលទាក់ទងទៅនឹងធនធានធម្មជាតិនិងបរិស្ថាន ។ល។ | |
| ២០ | អន្តរាគមន៍ផ្នែកសង្គមកិច្ច | សមាគមសង្គ្រោះ សមាគមចាស់ជរា ការផ្សព្វផ្សាយសិទ្ធិកុមារ ការបណ្តុះបណ្តាលនិងផ្សព្វផ្សាយអំពីអំពើហិង្សាក្នុងគ្រួសារ អំពីការជួញដូរស្ត្រីនិងកុមារ អំពីតួនាទីស្ត្រីនៅក្នុងសង្គម ។ល។ | សមាជិកសមាគម ។ គ្រួសារដែលទទួលបាននូវការបណ្តុះបណ្តាល ។ |

៣. អ្នកសំរបសំរួល ពន្យល់អំពីតារាងជំនួយស្មារតីទី៥ ។ ការបំពេញតារាងទី៥ ផ្អែកតាមពត៌មាននៃតារាងទី២ (ដំណោះស្រាយស្នើឡើងនៅភូមិ) តារាងទី៣.២ និងតារាងទី៤ ។ ក្នុងករណីខ្លះ តារាងទាំងនេះ មិនមានពត៌មានលំអិតគ្រប់គ្រាន់ ដូចនេះ ត្រូវការការបញ្ជាក់ពីតំណាងភូមិដែលជាសមាជិក គ.ផ.ថ ។

៤. លំហាត់ទី៥ : ចូរបំពេញតារាងជំនួយស្មារតីទី៥ ។ អ្នកសំរបសំរួល បែងចែកសិក្ខាកាមជា៣ក្រុម ។ ក្រុមនីមួយៗ បំពេញតារាងជំនួយស្មារតីទី៥ ដោយផ្អែកតាមពត៌មាននៃតារាងទី២ តារាងទី៣.២ តារាងទី៤ និងតារាងប៉ាន់ស្មានតំលៃគំរោង ។

៥. ក្រុមនីមួយៗ បង្ហាញតារាងលទ្ធផលរបស់ខ្លួន និងលើកឡើងនូវការលំបាក ឬបញ្ហានានាដែលបានជួបប្រទះក្នុងការពិភាក្សា ឬគិតថានឹងជួបប្រទះ ។ អ្នកសំរបសំរួល កត់ត្រានូវរាល់ការលំបាកដែលក្រុមនីមួយៗបានលើកឡើង បន្ទាប់មក ពិភាក្សាទៅលើចំណុចទាំងនោះ ជាមួយសិក្ខាកាម ។

៦. អ្នកសំរបសំរួល បូកសរុបលទ្ធផលនៃក្រុមពិភាក្សាតាមក្រុម ដោយបង្ហាញចំលើយនៃលំហាត់នេះ (ដែលបានរៀបចំនៅលើក្រដាសផ្ទាំងធំ) ។

## តារាងជំនួយស្មារតីទី៥

| ល.រ | ឈ្មោះគំរោង | គំរោងឆ្នាំមុន | ប្រភេទគំរោង | ចំនួនលទ្ធផល | ទីតាំងគំរោង | តំលៃប៉ាន់ស្មាន | អ្នកទទួលផល | | អាទិភាព | យោបល់ឯកភាពរបស់ជនជាតិដើមភាគតិច |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ប្រភេទ | ចំនួន | | |
| សេដ្ឋកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| សង្គមកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ធនធានធម្មជាតិ និងបរិស្ថាន | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| សេវាកម្មរដ្ឋបាល និងសន្តិសុខ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| យេនឌ័រ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

## តារាងតំលៃប៉ាន់ស្មានគំរោង

| គំរោង | លក្ខណៈវិនិច្ឆ័យសំរាប់ប្រើប្រាស់ | ផ្សេងៗ |
|---|---|---|
| ការងារដីៈ គ្រួសក្រហម | ៣.០០០ ដុល្លារ/ គ.ម | គិតក្នុងចំងាយមធ្យមទៅកាន់កន្លែងយកគ្រួសក្រហមប៉ុណ្ណោះ |
| ការជីកដី ( ប្រលាយ, ផ្លូវ, អាងស្តុកទឹក, ទំនប់ទឹក) | ១ ដុល្លារ/ ម៉ែត្រគ្រីគុណ | |
| វត្ថុបណ្តុះបណ្តាល | ថ្លៃសំភារៈបណ្តុះបណ្តាល..... | |
| | ថ្លៃបណ្តុះបណ្តាល ៣,៥ដុល្លារ/ថ្ងៃ និងបូកតំលៃធ្វើដំណើរ | |
| ការសាងសង់ៈ សាលារៀន ( ធ្វើអំពីថ្ម) | ៥.០០០ ដុល្លារ/ ១បន្ទប់ | |
| សាលាឈើ | ៣.០០០ ដុល្លារ/ ១បន្ទប់ | |
| ការសាងសង់ទ្វារទឹក (គំរោងខ្នាតតូច) | ១០.០០០ ដុល្លារ / ទ្វារទឹក | |
| លូកាត់ថ្នល់ (៥ កង់) មុខកាត់១ម | ៨០០ ដុល្លារ/ លូ | |
| លូកាត់ថ្នល់ (៥ កង់) មុខកាត់០.៨ម | ៦០០ ដុល្លារ/ លូ | |
| លូកាត់ថ្នល់ (៥ កង់) មុខកាត់០.៦ម | ៣៥០ ដុល្លារ/ លូ | |
| អណ្តូង (អណ្តូងលូជីកដោយដៃ) | ៣០០ ដុល្លារ/ អណ្តូង | |
| អណ្តូង (អណ្តូងស្នប់) | ៦០០ ដុល្លារ/ អណ្តូង | |
| ស្ពានថ្ម | ១.០០០ដុល្លារ/ ម | |
| ស្ពានឈើ | ២៥០ដុល្លារ/ម | |
| គ្រឿងសង្ហារិម | ២០ដុល្លារ/ សំរាប់ | |
| ការងារជួសជុល | ប៉ាន់ស្មានពេលវេលា ដែលត្រូវការសំរាប់ការងារ/ថ្លៃឈ្នួលក្នុង១ថ្ងៃ | |

# ប្លង់មេរៀនជំហានទី៦
# ការព្យាករណ៍ទុនវិនិយោគ

គោលបំណង : សិក្ខាកាមយល់ និងមានសមត្ថភាពក្នុងការជួយដល់ឃុំ សង្កាត់ ដើម្បីរៀបចំការប៉ាន់ស្មានចំណូលរបស់ខ្លួនសំរាប់រយៈពេល៣ឆ្នាំ ។



រយៈពេល : ប្រហែល៣០នាទី ។



សំភារៈចាំបាច់ : តារាងជំនួយស្មារតីទី៦រៀបចំនៅលើក្រដាសផ្ទាំងធំ ក្រដាសផ្ទាំងធំសំរាប់សរសេរ ហ្វឺត និងស្កុត ។

វិធីសាស្ត្រ : ការបង្ហាញ សំណួរ និងចំលើយ ។



កំណត់ចំណាំសំរាប់គ្រូឧទ្ទេស : អ្នកសំរបសំរួល ត្រូវបញ្ជាក់ប្រាប់សិក្ខាកាមថា នៅពេលពួកគេ សំរបសំរួលជាក់ស្តែងជាមួយ គ.ជ.ថ ត្រូវព្យាយាមបំពេញតារាងទី៦នេះអោយបានចប់សព្វគ្រប់ ទោះបីជាគេមិនទាន់បានដឹងតួលេខថវិកាក៏ដោយ ។ បើពុំទាន់បានទទួលពត៌មានអំពីថវិកា តួលេខថវិកាឆ្នាំកន្លងទៅ អាចប្រើជាមូលដ្ឋាននៃការគិត ។ តួលេខថវិកាប៉ាន់ស្មាននេះមានសារៈសំខាន់ណាស់ សំរាប់អនុវត្តនៅជំហានបន្ទាប់ ។

អ្នកសំរបសំរួល ត្រូវបញ្ជាក់ដល់មេឃុំ ចៅសង្កាត់ ផងដែរថា ជនបង្គោលទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ នឹងចូលរួមក្នុងការពិភាក្សានៅជំហាននេះ ។

របៀបសំរបសំរួលមេរៀន :



១. អ្នកសំរបសំរួល ចាប់ផ្តើមដោយបង្ហាញអំពីគោលបំណងនៃការប៉ាន់ស្មានចំណូលសំរាប់រយៈពេល៣ឆ្នាំ "ការកសាងផែនការដែលមិនបានគិតពិចារណាអំពីធនធានហិរញ្ញវត្ថុ មិនមានន័យអ្វីទេ" ។ ជាការសំខាន់ណាស់ ក្នុងការប៉ាន់ស្មានអំពីចំណូល ទោះបីជាបានដឹងពីធានធានជាក់ស្តែងរបស់ខ្លួនតិចតួចក៏ដោយ ។ គ.ជ.ថ អាចសន្មត់ថា ថវិកាឃុំ សង្កាត់របស់ខ្លួន នឹងមានការកើនឡើងបន្តិចបន្តួចជាងឆ្នាំកន្លងមក ។

ក្នុងដំណាក់កាលនេះ គ.ជ.ថ នឹងមិនរៀបចំគំរោងថវិកាទេ (Budget) ។ ពួកគេ គ្រាន់តែពិចារណាប៉ាន់ស្មានទូវធនធានសំរាប់គោលបំណងនៃការកសាងផែនការប៉ុណ្ណោះ ។

២. អ្នកសំរបសំរួល បង្ហាញតារាងជំនួយស្មារតីទី៦ ។ លទ្ធភាពធនធានថវិកាដែលបានប៉ាន់ស្មាននេះតិច ឬ ច្រើនត្រូវស៊ីគ្នាទៅនឹងតារាងទី៣.ក (នៅជំហានទី៥) នៅផ្នែក "គំរោងដែលទទួលបានថវិកាគាំទ្រ" ។

## តារាងជំនួយស្មារតីទី៦ : ការព្យាករណ៍ទុនវិនិយោគ

| លេខកូដ | ខ្ទង់ថវិកា | ២០០... | ២០០... | ២០០... |
|---|---|---|---|---|
| | **ចំណូលមូលធន** | | | |
| ៧៦ | ចំណូលមូលនិធិបំរុង | | | |
| ៧៧ | ចំណូលពីការផ្ទេរមូលនិធិឃុំសង្កាត់សំរាប់អភិវឌ្ឍន៍មូលដ្ឋាន | | | |
| ៧៨ | ចំណូលពីការរួមចំណែករបស់ប្រជាជនទៅក្នុងតំលៃគំរោង | | | |
| ៧៩ | ចំណូលមូលធនផ្សេងៗ | | | |
| | សរុបចំណូលមូលធន | | | |
| | **ចំណាយមូលធន** | | | |
| ៦៧ | ចំណាយវិនិយោគផ្នែករដ្ឋបាល | | | |
| ៦៨ | ចំណាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន | | | |
| | សរុបចំណាយមូលធន | | | |

កំណត់សំគាល់ :

- មូលនិធិឃុំ សង្កាត់ចំនួន២/៣ (ពីរភាគបី) ប្រើប្រាស់សំរាប់តែការវិនិយោគផ្នែកអភិវឌ្ឍន៍មូលដ្ឋាន ។
- ការវិនិយោគផ្នែករដ្ឋបាល ត្រូវប្រើប្រាស់ធនធានថវិកាមកពីប្រភពផ្សេង ។

# ប្លង់មេរៀនជំហានទី៧
## ការរៀបចំតារាងគំរោងវិនិយោគជាអាទិភាព

គោលបំណង : សិក្ខាកាម យល់ និងមានសមត្ថភាពជួយដល់ គ.ជ.ផ ក្នុងការរៀបចំតារាងជំនួយស្មារតីទី៧ និងការត្រៀមរៀបចំសំរាប់សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ ។



រយៈពេល : ប្រហែល១ម៉ោង ។



សំភារៈចាំបាច់ : លទ្ធផលជំហានទី៥ តារាងជំនួយស្មារតីទី៧ដែលរៀបចំលើក្រដាសផ្ទាំងធំ ក្រដាសផ្ទាំងធំ ហ្វឺត និងស្កុត ។

វិធីសាស្ត្រ : ការបង្ហាញ ពិភាក្សាតាមក្រុម និងការបូកសរុប ។



កំណត់ចំណាំសំរាប់គ្រូឧទ្ទេស : នៅជំហាននេះ អ្នកសំរបសំរួល ត្រូវចាប់អារម្មណ៍ទៅលើការរៀបចំឯកសារសំរាប់បង្ហាញ និងការជ្រើសរើសតំណាងឃុំ សង្កាត់ សំរាប់ចូលរួម នៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ ។ អ្នកសំរបសំរួល ត្រូវបញ្ជាក់ដល់មេឃុំ ចៅសង្កាត់ ផងដែរថា ជនបង្គោលទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ នឹងចូលរួមក្នុងការពិភាក្សានៅជំហាននេះ ។

របៀបសំរបសំរួលមេរៀន :



១. អ្នកសំរបសំរួល ត្រូវចាប់ផ្តើមដោយលើកឡើងថា "នៅជំហានទី៧នេះ យើងនឹងរៀបចំតារាងគំរោងវិនិយោគជាអាទិភាព" ។ អ្នកសំរបសំរួល ត្រូវបញ្ជាក់ជាថ្មីម្តងទៀតថា "មានតែគំរោងដែលមានអាទិភាពខ្ពស់ទេ ដែលត្រូវបានស្រង់បញ្ចូលទៅក្នុងតារាងជំនួយស្មារតីទី៧" ។ បន្ទាប់មក អ្នកសំរបសំរួល ពន្យល់អំពីតារាងជំនួយស្មារតីទី៧ ។

២. លំហាត់ទី៧ : ចូរបំពេញតារាងជំនួយស្មារតីទី៧

អ្នកសំរបសំរួល ចែកសិក្ខាកាមជា៣ក្រុម ។ ក្រុមនីមួយៗ បំពេញតារាងជំនួយស្មារតីទី៧ ដោយផ្អែកតាមពត៌មានដែលបានចែកជូន ហើយបន្ទាប់មកក្រុមនីមួយៗ បង្ហាញលទ្ធផលរបស់ក្រុមខ្លួន និងលើកឡើងនូវការលំបាក ឬបញ្ហានានា ដែលបានជួបប្រទះក្នុងការពិភាក្សា ឬគិតថានឹងជួបប្រទះ ។ អ្នកសំរបសំរួល កត់ត្រានូវរាល់ការលំបាកដែលក្រុមនីមួយៗបានលើកឡើង បន្ទាប់មកពិភាក្សាទៅលើចំណុចទាំងនោះ ជាមួយសិក្ខាកាម ។

៣. អ្នកសំរបសំរួល បូកសរុបលទ្ធផលនៃក្រុមពិភាក្សាតាមក្រុម ដោយបង្ហាញចំលើយនៃលំហាត់នេះ (ដែលបានរៀបចំនៅលើក្រដាសផ្ទាំងធំ) ។

៥. អ្នកសំរបសំរួល បន្តដោយលើកសំណួរថា "តើ គ.ផ.ថ ត្រូវធ្វើអ្វីខ្លះជាមួយនឹងតារាងនេះ នៅពេលបំពេញចប់សព្វគ្រប់?" ។ (ផ្ញើជូនមន្ទីរផែនការខេត្ត ក្រុងសំរាប់ត្រៀមរៀបចំសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ អោយបាន២សប្តាហ៍មុន) ។

៦. អ្នកសំរបសំរួល បំផុសសំណួរ "តើ គ.ផ.ថ ត្រូវត្រៀមរៀបចំអ្វីខ្លះ ដើម្បីចូលរួម នៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ?" ។ អ្នកសំរបសំរួល កត់ត្រាចំលើយទាំងអស់នៅលើក្រដាសផ្ទាំងធំ និងធ្វើការបូកសរុប ។

តារាងជំនួយស្មារតីទី៧ : គម្រោងវិនិយោគជាអាទិភាពរបស់ សំរាប់បញ្ចូលទៅក្នុងសិក្ខាសាលាសមាហរណកម្មដែនការថ្នាក់ស្រុក ខណ្ឌ

| ល.រ | ឈ្មោះគម្រោង | ប្រភេទគម្រោង | ចំនួនលទ្ធផល | តំលៃប៉ាន់ស្មាន | ទីតាំងគម្រោង | អ្នកទទួលផល | | កំណត់សំគាល់ក្នុងសិក្ខាសាលាសមាហរណកម្មដែនការថ្នាក់ស្រុក ខណ្ឌ |
|---|---|---|---|---|---|---|---|---|
| | | | | | | សរុប | ស្រី | |
| សេដ្ឋកិច្ច | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សង្គមកិច្ច | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| ធនធានធម្មជាតិ និងបរិស្ថាន | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សេវាកម្មរដ្ឋបាល និងសន្តិសុខ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| យេនឌ័រ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

# ប្លង់មេរៀនជំហានទី៨
## សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ

គោលបំណង : សិក្ខាកាម យល់ និងអាចពន្យល់ ត.ផ.៤ អំពីដំណើរការនៃសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ ។

រយៈពេល : ប្រហែល៤៥នាទី ។

សំភារៈចាំបាច់ : បញ្ជីត្រួតពិនិត្យសំរាប់អ្នកសង្កេតការណ៍ កិច្ចព្រមព្រៀងបណ្តោះអាសន្ន ក្រដាសផ្ទាំងធំសំរាប់សរសេរ ហ្វឺត និងស្កត់ ។

វិធីសាស្ត្រ : ការបង្ហាញ ការបំផុសគំនិត ក្រុមពិភាក្សា និងបូកសរុប (សង្ខេប) ។

កំណត់ចំណាំសំរាប់គ្រូឧទ្ទេស : នៅមេរៀននេះ អ្នកសំរបសំរួល មិនចំណាយពេលវេលាច្រើនពេកទេ ពីព្រោះថា សេចក្តីណែនាំស្តីពីសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ នឹងមានការពន្យល់យ៉ាងលំអិតហើយ ។ ចំណុចសំខាន់នៃមេរៀននេះ គឺដឹកនាំសិក្ខាកាមអោយឆ្លុះបញ្ចាំងអំពីសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ កាលពីឆ្នាំកន្លងទៅ និងមតិយោបល់ដើម្បីកែលំអសិក្ខាសាលានេះ នាពេលអនាគត ។

របៀបសំរបសំរួលមេរៀន :

១. អ្នកសំរបសំរួល ចែកបញ្ជីត្រួតពិនិត្យខាងក្រោមនេះ ដល់សិក្ខាកាម ។ បន្ទាប់មកសិក្ខាកាមនឹងបំពេញចំលើយរៀង១ខ្លួន ។

២. អ្នកសំរបសំរួល បែងចែកសិក្ខាកាមជា៣ក្រុម ដើម្បីពិភាក្សាទៅលើប្រធានបទ "តើយើងអាចកែលំអសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌយ៉ាងដូចម្តេច?" ។ តំណាងក្រុមនីមួយៗ ឡើងបង្ហាញលទ្ធផលរបស់ខ្លួន ។

អ្នកសំរបសំរួល បូកសរុបលទ្ធផលនៃក្រុមទាំងអស់ និងបន្ទាប់មកលើកឡើង ជាការសន្និដ្ឋានថា ខេត្ត ក្រុងមានលទ្ធភាពបត់បែនជាច្រើន ក្នុងការរៀបចំ និងកែលំអសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ ។ ថ្នាក់ជាតិ គ្រាន់តែផ្តល់ជាសេចក្តីណែនាំ ហើយមិនតំរូវអោយអនុវត្តតាមដោយមិនអាចបត់បែននោះទេ ។

៣. នៅចុងបញ្ចប់នៃមេរៀននេះ អ្នកសំរបសំរួល ត្រូវបង្ហាញទំរង់ "កិច្ចព្រមព្រៀងបណ្តោះអាសន្ន" ។

# បញ្ជីត្រួតពិនិត្យ

| | | | |
|---|---|---|---|
| ១). | តើអភិបាល ឬអភិបាលរងខេត្ត ក្រុង បានចូលរួមដែរឬទេ? | មាន ☐ | គ្មាន ☐ |
| ២). | តើប្រធានមន្ទីរជំនាញខេត្ត ក្រុងបានចូលរួមដែរឬទេ? | មាន ☐ | គ្មាន ☐ |
| ៣). | បើមិនមែនប្រធានមន្ទីរ តើជាអនុប្រធានមន្ទីរ ឬតំណាងមន្ទីរដែលអាចធ្វើសេចក្តីសំរេចចិត្តបានដែរឬទេ? | មាន ☐ | គ្មាន ☐ |
| ៤). | តើឃុំ សង្កាត់បានបង្ហាញកម្មវិធីវិនិយោគរបស់ខ្លួនដែរឬទេ? | មាន ☐ | គ្មាន ☐ |
| ៥). | តើឃុំ សង្កាត់ គិតថាពួកគេមានពេលវេលាគ្រប់គ្រាន់ ក្នុងការបង្ហាញដែរឬទេ? | មាន ☐ | គ្មាន ☐ |
| ៦). | តើមន្ទីរជំនាញបានបង្ហាញផែនការរបស់ខ្លួនដែរឬទេ? | មាន ☐ | គ្មាន ☐ |
| ៧). | តើមានការពិភាក្សារវាងមន្ទីរជំនាញ និងឃុំ សង្កាត់ដែរឬទេ? | មាន ☐ | គ្មាន ☐ |
| ៨). | តើមានការពិភាក្សារវាងអង្គការមិនមែនរដ្ឋាភិបាល និងឃុំ សង្កាត់ដែរឬទេ? | មាន ☐ | គ្មាន ☐ |
| ៩). | ជាក់ស្តែង តើសិក្ខាសាលាសមាហរណកម្មនេះ ចំណាយពេលអស់ប៉ុន្មាន? | ១ថ្ងៃ ☐ | កន្លះថ្ងៃ ☐ |
| ១០). | តើសិក្ខាសាលាសមាហរណកម្មនេះរៀបចំនៅចំពេលសមស្របដែរឬទេ? | បាទ ☐ | ទេ ☐ |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង :.......................                                                                 ថ្ងៃទី.......... ខែ ............... ឆ្នាំ.........

## កិច្ចព្រមព្រៀងបណ្ដោះអាសន្ន

នៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកខណ្ឌសំរាប់ឆ្នាំ............. ដែលប្រព្រឹត្តទៅ នៅស្រុកខណ្ឌ...................... នាថ្ងៃទី..................... ឃុំ សង្កាត់............................ និង .................................. បានព្រមព្រៀងជាបណ្ដោះអាសន្ន លើកិច្ចសហការគ្នា ក្នុងការអនុវត្តគំរោងសំរាប់អភិវឌ្ឍន៍ឃុំ សង្កាត់ ដូចតទៅ :

| លរ | ឈ្មោះគំរោង | ទីតាំងគំរោង | ការសន្យាគាំទ្រ | | ការចូលរួម របស់មូលដ្ឋាន |
|---|---|---|---|---|---|
| | | | ទំហំគំរោង | ថវិកាជាន់ស្មាន | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

តំណាងមន្ទីរជំនាញ ឬអង្គការ                                                  មេឃុំ ចៅសង្កាត់

ហត្ថលេខា                                                                           ហត្ថលេខា

សាក្សីអភិបាលស្រុក ខណ្ឌ                                                  មន្ទីរផែនការខេត្ត ក្រុង

ហត្ថលេខា                                                                           ហត្ថលេខា

# ប្លង់មេរៀនជំហានទី៩

## ការសំរេចចុងក្រោយលើគំរោងនានាក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់

គោលបំណង : សិក្ខាកាម យល់ និងអាចជួយដល់ គ.ផ.ថ ក្នុងការសំរេចចុងក្រោយលើគំរោងនានា ក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ និងការបំពេញតារាងទី៣.ក និង ទី៣.ខ ។



រយៈពេល : ប្រហែល៣ម៉ោង ។



សំភារៈចាំបាច់ : លទ្ធផលពីជំហានទី៥ដល់ទី៨ តារាងមិនទាន់បំពេញនៃជំហានទី៩ ឯកសារលំហាត់ ក្រដាសផ្ទាំងធំសំរាប់សរសេរ ហ្វឺត និងស្កត់ ។

វិធីសាស្ត្រ : ការបង្ហាញ លំហាត់ ការពិភាក្សា និងសំណួរចំលើយ ។



កំណត់ចំណាំសំរាប់គ្រូឧទ្ទេស : អ្នកសំរបសំរួល ត្រូវពន្យល់យឺតៗ និងច្បាស់លាស់នូវវិធីសាស្ត្រនៃការពិចារណាគំរោងទាំងបី (ក ខ) ដើម្បីកុំអោយសិក្ខាកាមច្រឡូកច្របល់ ហើយព្យាយាមលើកទឹកចិត្តអ្នកសំរបសំរួលស្រុក ខណ្ឌ ក្នុងការប្រើប្រាស់វិធីសាស្ត្រទាំងនេះ នៅពេលអនុវត្តផ្ទាល់ជាមួយ គ.ផ.ថ ។ អ្នកសំរបសំរួល ត្រូវបញ្ជាក់ដល់មេឃុំ ចៅសង្កាត់ផងដែរថា ជនបង្គោលទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ នឹងចូលរួមក្នុងការពិភាក្សានៅជំហាននេះ ។

របៀបសំរបសំរួលមេរៀន :



១. អ្នកសំរបសំរួល ចាប់ផ្តើមដោយលើកឡើងថា "នៅជំហានទី៩នេះ យើងនឹងរៀបចំតារាងគំរោងវិនិយោគឃុំ សង្កាត់៣ឆ្នាំរំកិល" ។ ដើម្បីអនុវត្តជំហាននេះ យើងត្រូវការលទ្ធផលនៃជំហានទី៥ ជំហានទី៦ ជំហានទី៧ និងជំហានទី៨ (លទ្ធផលពីសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ) ។

អ្នកសំរបសំរួល ត្រូវបញ្ជាក់ជាថ្មីម្តងទៀតថា "មានតែគំរោងដែលជាអាទិភាពខ្ពស់ ហើយមិនបានទទួលការគាំទ្រថវិកាពីប្រភពខាងក្រៅទេ ដែលត្រូវយកមកពិចារណាក្នុងការប្រើប្រាស់ធនធានថវិកាផ្ទាល់របស់ឃុំ សង្កាត់" ។

អ្នកសំរបសំរួល ពន្យល់អំពីតារាងទី៣.ក និង៣.ខ ព្រមទាំងលើកឧទាហរណ៍ ។

២. អ្នកសំរបសំរួល ពន្យល់ពីលក្ខណៈវិនិច្ឆ័យទាំង៦ ក្នុងការប្រើប្រាស់ធនធានថវិកាផ្ទាល់របស់ឃុំ សង្កាត់ ដោយបង្ហាញតារាងវិភាគ ។ ខាងក្រោមនេះ គឺជាលក្ខណៈវិនិច្ឆ័យទាំង៦ :

(១). គំរោងបំរើផលប្រយោជន៍អោយប្រជាជនភាគច្រើន ។ (ត្រូវចាំទុកថាគំរោងមួយចំនួនអាចផ្តល់ផលប្រយោជន៍ដោយប្រយោលដល់ប្រជាជនភាគច្រើន) ។

(២). គំរោងទាំងឡាយ ដែលមានបទដ្ឋានបច្ចេកទេសសមស្រប ។

(៣). គំរោងដែលធានាបាននូវនិរន្តរភាពផ្នែកបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

(៤). គំរោងដែលមានផលប៉ះពាល់ជាវិជ្ជមានដល់ស្ត្រី និងកុមារ ។

(៥). គំរោង ដែលមាននិរន្តរភាព ។

(៦). គំរោងដែលឆ្លើយតបនឹងសេចក្តីត្រូវការបន្ទាន់ និងមានអាទិភាពខ្ពស់ ។

តារាងវិភាគគំរោងទៅនឹងលក្ខណៈវិនិច្ឆ័យ

| លរ | គំរោង | លក្ខណៈវិនិច្ឆ័យ | | | | | | ឆ្លើយតបគ្រប់លក្ខណៈវិនិច្ឆ័យ |
|---|---|---|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 | 5 | 6 | |
| ១ | ដំណាំឈើហូបផ្លែតាមគ្រួសារ | | | | | | | |
| ២ | បណ្តុះបណ្តាលការប្រើប្រាស់ជីកំប៉ុស្តិ៍ និងជីគីមី | | | | | | | |
| ៣ | ធនាគារជីគីមី | | | | | | | |
| ៤ | សាងសង់ស្ពាន១កន្លែង និងលូ២កន្លែង | | | | | | | |
| ៥ | សម្ភារៈសំរាប់សាលារៀន | | | | | | | |
| ៦ | ជីកអណ្តូងលូ១០ និងស្នប់១៥ | | | | | | | |
| ៧ | បង្គន់អនាម័យតាមគ្រួសារ | | | | | | | |
| ៨ | ផ្សព្វផ្សាយ និងដាំដើមឈើឡើងវិញ | | | | | | | |
| ៩ | ក្តារពត៌មានភូមិ និងឃុំ | | | | | | | |
| ១០ | បណ្តុះបណ្តាលនិងផ្សព្វផ្សាយអំពើហឹង្សាក្នុងគ្រួសារ | | | | | | | |

៣. បន្ទាប់មកទៀត អ្នកសំរបសំរួល បន្តដោយលើកឡើងថា "ឥឡូវនេះ យើងព្យាយាមធ្វើការពិចារណាទៅលើគំរោងជាអាទិភាពដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យទាំងអស់" ។

ក). វិធីសាស្ត្រដាក់ពិន្ទុ : អ្នកសំរបសំរួល ចែកតារាងសំរាប់ដាក់ពិន្ទុគំរោង (មានភ្ជាប់មកជាមួយ) ទៅគ្រប់សិក្ខាកាម បន្ទាប់មកសិក្ខាកាមម្នាក់ៗ ដាក់ពិន្ទុទៅតាមចំណូលចិត្តរបស់ខ្លួន ដែលមាន១ ដល់ ១០ (ប្រសិនបើឃុំមាន១២គំរោង ពិន្ទុមានពី ១ ដល់១២) ។ គំរោងណាដែលខ្លួនចូលចិត្តជាងគេបំផុត ត្រូវដាក់លេខ១០ លេខ៩ លេខ៨ រហូតដល់គំរោងចុងក្រោយគេ គឺលេខ១ ។

បន្ទាប់មក អ្នកសំរបសំរួល ត្រូវបូកសរុបពិន្ទុនៃសិក្ខាកាមទាំងអស់បញ្ចូលគ្នា ។ គំរោងទាំងនេះត្រូវតំរៀបតាមលំដាប់លំដោយ ផ្អែកទៅតាមពិន្ទុ ។ គំរោងដែលបានពិន្ទុច្រើនជាងគេ ត្រូវដាក់លេខ១ (មានន័យថា គឺជាគំរោងដែលមានអាទិភាពខ្ពស់ជាងគេបំផុត) ជាបន្តបន្ទាប់រហូតដល់លេខ១០ ។

## វិធីសាស្ត្រដាក់ពិន្ទុ

| គំរោង | ពិន្ទុ |
|---|---|
| ដណាំឈើហូបផ្លែតាមគ្រួសារ | |
| បណ្តុះបណ្តាលអំពីការប្រើប្រាស់ជីកំប៉ុស្តិ៍ និងជីគីមី | |
| ធនាគារជីគីមី | |
| សាងសង់ស្ពាន១កន្លែង និងលូ២កន្លែង | |
| សង្ហារឹមសំរាប់សាលារៀន | |
| ជីកអណ្តូងលូ១០ និងស្នប់១៥ | |
| បង្កន់អនាម័យតាមគ្រួសារ | |
| ផ្សព្វផ្សាយ និងដាំដើមឈើឡើងវិញ | |
| ក្តារពត៌មានភូមិ និងឃុំ | |
| បណ្តុះបណ្តាល និងផ្សព្វផ្សាយអំពើហឹង្សាក្នុងគ្រួសារ | |

បើ សមាជិក គ.ផ.ថ មានចំនួនច្រើន អ្នកសំរបសំរួល អាចអោយ គ.ផ.ថ នៃភូមិនីមួយៗដាក់ពិន្ទុរួមគ្នាតែម្តង (១ភូមិមានតារាងដាក់ពិន្ទុ១) ដោយមិនចាំបាច់អោយ គ.ផ.ថ ម្នាក់ៗដាក់ពិន្ទុដោយឡែកៗនោះទេ។

## សំរាប់ការបូកសរុបពិន្ទុ

| គំរោង | ពិន្ទុរបស់សិក្ខាកាមទី | | | | | | | ពិន្ទុសរុប | លេខអាទិភាព |
|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | ..... | | |
| ដណាំឈើហូបផ្លែតាមគ្រួសារ | | | | | | | | | |
| បណ្តុះបណ្តាលការប្រើប្រាស់ជីកំប៉ុស្តិ៍និងជីគីមី | | | | | | | | | |
| ធនាគារជីគីមី | | | | | | | | | |
| សាងសង់ស្ពាន១កន្លែង និងលូ២កន្លែង | | | | | | | | | |
| សង្ហារឹមសំរាប់សាលារៀន | | | | | | | | | |
| ជីកអណ្តូងលូ១០ និងស្នប់១៥ | | | | | | | | | |
| បង្កន់អនាម័យតាមគ្រួសារ | | | | | | | | | |
| ផ្សព្វផ្សាយ និងដាំដើមឈើឡើងវិញ | | | | | | | | | |
| ក្តារពត៌មានភូមិ និងឃុំ | | | | | | | | | |
| បណ្តុះបណ្តាលនិងផ្សព្វផ្សាយអំពើហឹង្សាក្នុងគ្រួសារ | | | | | | | | | |

ខ). វិធីសាស្ត្រផ្ទូរផ្ទង : អ្នកសំរបសំរួល បិទក្រដាសផ្ទាំងធំដែលជាតារាងគំរោងដែលដាក់រាយតាមលក្ខណៈផ្តេក និងបញ្ឈរ ។ បន្ទាប់មក អ្នកសំរបសំរួល សួរទៅកាន់សិក្ខាកាម ដើម្បីប្រៀបធៀបគំរោងម្តង១គូ១ ។ លេខ របស់គំរោងដែលទទួលបាននូវការចូលចិត្តជាង ត្រូវសរសេរក្នុងប្រអប់ដែលនៅចំចន្លោះនៃការប្រៀបធៀបគំរោងទាំងពីរ ។ គំរោង ដែលទទួលបាននូវសំលេង ច្រើនជាងគេ គឺជាគំរោង ដែលគេពេញចិត្តជាងគេ ។ ពិន្ទុសរុបសំរាប់គំរោងនីមួយៗ គឺដាក់នៅជួរក្រោមគេបង្អស់ ។

## វិធីសាស្ត្រផ្ទូរផ្ទង

| គំរោង | | ១ ឈើហូបផ្លែតាមគ្រួសារ | ២ បណ្តុះដីគីមី-ដីកំប៉ុស្តិ៍ | ៣ ធនាគារដីគីមី | ៤ សាងសង់ស្ពាន១ និងលូ២ | ៥ សង្ហារិមសំរាប់សាលារៀន | ៦ ជីកអណ្តូងលូ និងស្តូប | ៧ បង្កន់តាមគ្រួសារ | ៨ ដាំដើមឈើឡើងវិញ | ៩ ក្តារពត៌មានឃុំ និងភូមិ | ១០ អំពើហិង្សាក្នុងគ្រួសារ |
|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ឈើហូបផ្លែតាមគ្រួសារ | | | | | | | | | | |
| ២ | បណ្តុះដីគីមី-ដីកំប៉ុស្តិ៍ | | | | | | | | | | |
| ៣ | ធនាគារដីគីមី | | | | | | | | | | |
| ៤ | សាងសង់ស្ពាន១ និងលូ២ | | | | | | | | | | |
| ៥ | សង្ហារិមសំរាប់សាលារៀន | | | | | | | | | | |
| ៦ | ជីកអណ្តូងលូ និងស្តូប | | | | | | | | | | |
| ៧ | បង្កន់តាមគ្រួសារ | | | | | | | | | | |
| ៨ | ដាំដើមឈើឡើងវិញ | | | | | | | | | | |
| ៩ | ក្តារពត៌មានឃុំ និងភូមិ | | | | | | | | | | |
| ១០ | អំពើហិង្សាក្នុងគ្រួសារ | | | | | | | | | | |
| ពិន្ទុសរុប | | | | | | | | | | | |

វិធីសាស្ត្រក្នុងការពិចារណាគំរោងដែលបានពិពណ៌នាខាងលើ គឺគ្រាន់តែជាជំរើសមួយចំនួនប៉ុណ្ណោះ ។ គ.ជ.ថ អាចជ្រើសរើសយកវិធីសាស្ត្រណាមួយក្នុងចំណោមវិធីសាស្ត្រទាំងនោះ ដើម្បីជ្រើសរើសគំរោងសំរាប់ប្រើប្រាស់ធនធានថវិកាឃុំ សង្កាត់ ។ កន្លងមក គ.ជ.ថ ភាគច្រើនប្រើប្រាស់តែវិធីសាស្ត្របោះឆ្នោត (ការលើកដៃ) ប៉ុណ្ណោះ ឥឡូវនេះ ពួកគេមានជំរើសច្រើន ។

៤. លំហាត់ទី៩ : ចូរបំពេញតារាងទី៣.ក និង៣.ខ

អ្នកសំរបសំរួល បែងចែកសិក្ខាកាមជា៣ក្រុម ដើម្បីបំពេញតារាងទី៣.ក និង៣.ខ ដោយផ្អែកតាមពត៌មានដែលបានផ្តល់ជូន ។ ក្រុមនីមួយៗ បំពេញតារាងទាំងពីរនេះ ។

អ្នកសំរបសំរួល ត្រូវជំរាបដល់ក្រុមពិភាក្សាថា "ក្រុមនីមួយៗអាចជ្រើសរើសយកវិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រដែលបានបង្ហាញខាងលើ ដើម្បីពិចារណាទៅលើគំរោង ក្នុងការប្រើប្រាស់ធនធានថវិកាឃុំ សង្កាត់" ។ នៅក្នុងការពិភាក្សា ក្រុមនីមួយៗ ត្រូវកត់ត្រានូវការលំបាក ឬចំណុចណាដែលមិនទាន់ច្បាស់ ។

ក្រុមនីមួយៗ បង្ហាញលទ្ធផល និងការលំបាកក្នុងការបំពេញតារាងទាំង២ របស់ក្រុមខ្លួន ។ អ្នកសំរបសំរួល កត់ត្រានូវរាល់ការលំបាកទាំងនេះ ហើយបន្ទាប់មក ពិភាក្សាជាមួយសិក្ខាកាម ។

## តារាង ៣.ក : តារាងវិនិយោគឃុំ សង្កាត់៣ឆ្នាំរំកិល

| ល.រ | ឈ្មោះគំរោង | ទីតាំងគំរោង | ចំនួនលទ្ធផល | | | តំលៃចាំន់ស្មាន | អ្នកទទួលផល | | អ្នកសិក្សាគំរោង | ប្រភពគាំទ្រថវិកា | អ្នកទទួលបន្ទុក |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០០៤ | ២០០៥ | ២០០៦ | | សរុប | ស្រី | | | |
| **គំរោងកំពុងដំណើរការ (បើមាន)** | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| **គំរោងវិនិយោគដែលមានការគាំទ្រ** | | | | | | | | | | | |
| **ក). ផ្នែកសេដ្ឋកិច្ច** | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | សរុបតំលៃចាំន់ស្មានផ្នែកសេដ្ឋកិច្ច | | | | | | |
| **ខ). ផ្នែកសង្គមកិច្ច** | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | សរុបតំលៃចាំន់ស្មានផ្នែកសង្គមកិច្ច | | | | | | |

| ល.រ | ឈ្មោះគំរោង | ទីតាំងគំរោង | ចំនួនលទ្ធផល | | | តំលៃចាប់ស្មាន | អ្នកទទួលផល | | អ្នកសិក្សាគំរោង | ប្រភពគាំទ្រថវិកា | អ្នកទទួលបន្ទុក |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០០៤ | ២០០៥ | ២០០៦ | | សរុប | ស្រី | | | |
| គ). ផ្នែកធនធានធម្មជាតិ និងបរិស្ថាន | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| សរុបតំលៃចាប់ស្មានផ្នែកធនធានធម្មជាតិ និងបរិស្ថាន | | | | | | | | | | | |
| ឃ). ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| សរុបតំលៃចាប់ស្មានផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ | | | | | | | | | | | |
| ង). ផ្នែកយេនឌ័រ | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| សរុបតំលៃចាប់ស្មានផ្នែកយេនឌ័រ | | | | | | | | | | | |
| សរុបរួមតំលៃចាប់ស្មានគំរោងមានការគាំទ្រ | | | | | | | | | | | |

| លរ | ឈ្មោះគំរោង | ទីតាំងគំរោង | ចំនួនលទ្ធផល | | | តំលៃចាំនស្មាន | អ្នកទទួលផល | | អ្នកសិក្សាគំរោង | ប្រភពគាំទ្រថវិកា | អ្នកទទួលបន្ទុក |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០០៤ | ២០០៥ | ២០០៦ | | សរុប | ស្រី | | | |
| គំរោងវិនិយោគដែលគ្មានការគាំទ្រ | | | | | | | | | | | |
| ក). ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| សរុបតំលៃចាំនស្មានផ្នែកសេដ្ឋកិច្ច | | | | | | | | | | | |
| ខ). ផ្នែកសង្គមកិច្ច | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| សរុបតំលៃចាំនស្មានផ្នែកសង្គមកិច្ច | | | | | | | | | | | |
| គ). ផ្នែកធនធានធម្មជាតិ និងបរិស្ថាន | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| សរុបតំលៃចាំនស្មានផ្នែកធនធានធម្មជាតិ និងបរិស្ថាន | | | | | | | | | | | |

| លរ | ឈ្មោះគំរោង | ទីតាំងគំរោង | ចំនួនលទ្ធផល | | | តំលៃចាប់ស្មាន | អ្នកទទួលផល | | អ្នកសិក្សាគំរោង | ប្រភពគាំទ្រថវិកា | អ្នកទទួលបន្ទុក |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០០៤ | ២០០៥ | ២០០៦ | | សរុប | ស្រី | | | |
| ឃ). ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| សរុបតំលៃចាប់ស្មានផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ | | | | | | | | | | | |
| ង). ផ្នែកយេនឌ័រ | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| សរុបតំលៃចាប់ស្មានផ្នែកយេនឌ័រ | | | | | | | | | | | |
| សរុបរួមតំលៃចាប់ស្មានគំរោងគ្មានការគាំទ្រ | | | | | | | | | | | |

## តារាង ៣.ខ : តារាងថវិកាវិនិយោគតាមប្រភពផ្តល់

| លរ | ប្រភពថវិកា | ឆ្នាំ២០០៤ | ភាគរយ (%) |
|---|---|---|---|
| ១ | ធនធានផ្ទាល់ខ្លួន (រួមទាំងការចូលរួមរបស់ប្រជាជន) | | |
| ២ | មូលនិធិឃុំ សង្កាត់ | | |
| ៣ | សរុបរងទុនភ្នាក់ងារនានាពីក្រៅ | | |
| **សរុបរួម** | | | ១០០% |
| ៣.១ | មន្ទីរ................................................ | | |
| ៣.២ | មន្ទីរ................................................ | | |
| ៣.៣ | អង្គការក្រៅរដ្ឋាភិបាល......................... | | |
| ៣.៤ | ភ្នាក់ងារ........................................... | | |
| ៣.៥ | សប្បុរសជន........................................ | | |

## លំហាត់ទី៩ : ចូរបំពេញតារាងទី៣.ក និង៣.ខ

ក). លទ្ធផលជំហានទី៥

ខ). លទ្ធផលជំហានទី៦ :

ឃុំ ទទួលបានថវិកាពីមូលនិធិឃុំ សង្កាត់ ឆ្នាំ២០០៤ = ៧.០០០ដុល្លារ ឆ្នាំ២០០៥ = ៨.០០០ដុល្លារ និង ឆ្នាំ២០០៦ = ៩.០០០ដុល្លារ ។

គ). លទ្ធផលជំហានទី៧

ឃ). បញ្ជីគំរោងដែលទទួលបានការគាំទ្រថវិកា នៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការ គំរោងខាងក្រោមនេះជាគំរោង ដែលគាំទ្រដោយមន្ទីរជំនាញ និង អង្គការមិនមែនរដ្ឋាភិបាល :

១. គំរោងធ្វើសួនបន្លែតាមផ្ទះ (២០០ដុល្លារ) គាំទ្រដោយអង្គការ "ខ្មែរជួយខ្មែរ"

២. ធនាគារគោ (១០.០០០ ដុល្លារ) គាំទ្រ ដោយមន្ទីរកសិកម្ម (គំរោង IFAD)

៣. ជួសជុលផ្លូវប្រវែង៣ គម (៩.០០០ ដុល្លារ) គាំទ្រដោយមន្ទីរអភិវឌ្ឍន៍ជនបទ

៤. សាងសង់មណ្ឌលសុខភាព (២០.០០០ ដុល្លារ) គាំទ្រដោយក្រសួងសុខាភិបាល

៥. ជួសជុលសាលារៀន៦បន្ទប់ (៣.០០០ ដុល្លារ) គាំទ្រដោយក្រសួងអប់រំ

៦. ថ្នាក់អក្ខរកម្ម (២.០០០ ដុល្លារ) គាំទ្រដោយអង្គការ "អភិវឌ្ឍន៍ធនធានមនុស្ស"

៧. ជ្រើសរើស និងបណ្តុះបណ្តាលឆ្មបភូមិ (១.៥០០ដុល្លារ) គាំទ្រដោយអង្គការ "សុខភាពសង្គម"

៨. ការផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ (៨០០ ដុល្លារ) គាំទ្រដោយក្រសួងកិច្ចការនារី ។

៩. ឥណទានសាច់ប្រាក់ (៨.០០០ដុល្លារ) គាំទ្រដោយស្ថាប័នមីក្រូហិរញ្ញវត្ថុ "ហត្ថាកសិករ" ។

មន្ទីរជំនាញនានា និង NGOs នឹងផ្តល់សេវាកម្ម/ការគាំទ្រគំរោងដែលមិនមាននៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ ដូចតទៅនេះ ។

១. វគ្គបណ្តុះបណ្តាល IPM (៥០០ ដុល្លារ សំរាប់២វគ្គ នៅ២ភូមិ ដែលមានអ្នកចូលរួម៦០នាក់ ក្នុងនោះ ស្រី៣០នាក់) ដោយមន្ទីរកសិកម្ម ។

២. ការបង្ហាញពីពូជស្រូវ (៣០០ ដុល្លារ សំរាប់១០បង្ហាញ នៅ២ភូមិ ដែលមានអ្នកចូលរួម១០នាក់ ក្នុងនោះ ស្រី៥នាក់) ដោយមន្ទីរកសិកម្ម ។

# ប្លង់មេរៀនជំហានទី១០

## ការចងក្រងសៀវភៅកម្មវិធីវិនិយោគឃុំ សង្កាត់



គោលបំណង : សិក្ខាកាម យល់ និងអាចជួយដល់ គ.ជ.ថ ក្នុងការចងក្រងសៀវភៅកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ឃុំ សង្កាត់ ។



រយៈពេល : ប្រហែល២ម៉ោង ។



សំភារៈចាំបាច់ : លទ្ធផលនៃជំហានទី១ដល់ទី៩ ក្រដាសផ្ទាំងធំសំរាប់សរសេរ ហ្វឺត និងស្កត់ ។

វិធីសាស្ត្រ : សំណួរបំផុស ក្រុមពិភាក្សា ការបង្ហាញ និងសំណួរចំលើយ ។



កំណត់ចំណាំសំរាប់គ្រូឧទ្ទេស : ជំហានទី១០នេះ គឺជាដំណាក់កាលនៃការសរសេរតាក់តែង និងចងក្រងជាសៀវភៅកម្មវិធីវិនិយោគឃុំ សង្កាត់ ។ ដូចនេះ ត្រូវអោយអ្នកសំរបសំរួលយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពដល់ គ.ជ.ថ ដើម្បីអោយពួកគេមានសមត្ថភាពគ្រប់គ្រាន់ ។ លើសពីនេះទៀត អ្នកសំរបសំរួល ត្រូវ ព្យាយាមជំរុញដល់សមាជិក គ.ជ.ថ គ្រប់រូបចូលរួមផ្តល់គំនិតយោបល់ ក្នុងការរៀបចំនេះ ។

របៀបសំរបសំរួលមេរៀន :



១. ការបំផុសគំនិត : អ្នកសំរបសំរួល ចាប់ផ្តើមដោយលើកឡើងថា "កាលពីឆ្នាំកន្លងទៅ តើការចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់បានជួបប្រទះការលំបាកអ្វីខ្លះ?" ។ អ្នកសំរបសំរួល កត់ត្រាយោបល់ ឬចំលើយ នៅលើក្រដាសផ្ទាំងធំ ហើយបន្ទាប់មកពិភាក្សាជាមួយសិក្ខាកាមនូវមតិយោបល់ ឬចំលើយទាំងនោះ ។

២. អ្នកសំរបសំរួល បង្ហាញទំរង់កម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ឃុំ សង្កាត់ និងធ្វើការពន្យល់មួយចំណុចម្តងៗ ព្រមទាំងលើកឧទាហរណ៍ ។

៣. លំហាត់ទី១០ : អ្នកសំរបសំរួល ចែកសិក្ខាកាមជា៣ក្រុមស្មើៗគ្នា ។ ក្រុមនីមួយៗ ធ្វើការពិភាក្សា និងរៀបចំ អំពី :

- អារម្ភកថា
- សេចក្តីផ្តើម
- ទិសដៅបន្ទាន់ និងយុទ្ធសាស្ត្រនៃផ្នែកណាមួយក្នុងចំណោមផ្នែកទាំង៥ ។

បន្ទាប់មក ក្រុមនីមួយៗ បង្ហាញលទ្ធផលរបស់ក្រុមខ្លួន និងសំណួរចំលើយ ។

# ទំរង់ឯកសារកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ឃុំ សង្កាត់

អារម្ភកថា :

សេចក្តីផ្តើម :

ផែនទី :

## ជំពូកទី១ : ការវិភាគពីស្ថានភាពអភិវឌ្ឍន៍របស់ឃុំសង្កាត់

ក). ផ្នែកសេដ្ឋកិច្ច

ខ). ផ្នែកសង្គមកិច្ច

គ). ផ្នែកធនធានធម្មជាតិនិងបរិស្ថាន

ឃ). ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ

ង). ផ្នែកយេនឌ័រ

## ជំពូកទី២ : ទិសដៅបន្ទាន់ និងយុទ្ធសាស្ត្រសំរាប់ការវិនិយោគ

ក). ទិសដៅបន្ទាន់

ខ). យុទ្ធសាស្ត្រសំរាប់ការវិនិយោគ

## ជំពូកទី៣ : គំរោងវិនិយោគបីឆ្នាំរំកិល

ក). តារាងគំរោងវិនិយោគឃុំសង្កាត់បីឆ្នាំរំកិល

ខ). តារាងថវិកាវិនិយោគតាមប្រភពផ្តល់

ឧបសម្ព័ន្ធ : គឺជាឯកសារយោង ដើម្បីរំលេចខ្លឹមសារនៃចំនុចពាក់ព័ន្ធណាមួយ អោយកាន់តែច្បាស់លាស់ និងមានមូលដ្ឋានពិតប្រាកដ ។ ហេតុនេះ ការដាក់បញ្ចូលនូវឯកសារឧបសម្ព័ន្ធនោះ អាស្រ័យទៅលើការសំរេចចិត្តរបស់ គ.ជ.ថ ។

# ប្លង់មេរៀនទី១១

## ការរៀបចំអនុម័តឯកសារកម្មវិធីវិនិយោគឃុំ សង្កាត់



គោលបំណង : សិក្ខាកាម យល់ និងអាចពន្យល់ដល់ គ.ជ.ថ អំពី នីតិវិធីក្នុងការអនុម័តកម្មវិធីវិនិយោគឃុំ សង្កាត់ ។



រយៈពេល : ប្រហែល១ម៉ោង



សំភារៈចាំបាច់ : ឯកសារកម្មវិធីវិនិយោគ ក្រដាសផ្ទាំងធំសំរាប់សរសេរ ហ្វឺត និងស្កុត ។

វិធីសាស្ត្រ : សំណួរបំផុស ការបង្ហាញ និងសំណួរចំលើយ ។



កំណត់ចំណាំសំរាប់គ្រូឧទ្ទេស : មេរៀននេះ អ្នកសំរបសំរួល មិនត្រូវចំណាយពេលច្រើនពេក អ្វីដែលសំខាន់នៅពេលនេះ គឺពិនិត្យឡើងវិញនូវដំណើរការអនុម័តសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឆ្នាំកន្លងទៅ និងប្រមូលមតិយោបល់ដើម្បីកែលំអនាពេលអនាគត ។

របៀបសំរបសំរួលមេរៀន :



១. ការបំផុសគំនិត : អ្នកសំរបសំរួល ចាប់ផ្តើមដោយលើកឡើងថា "កាលពីឆ្នាំកន្លងទៅ តើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបានដំណើរការអនុម័តយ៉ាងដូចម្តេច?" ។ អ្នកសំរបសំរួល កត់ត្រាចំលើយនៅលើក្រដាសផ្ទាំងធំ ហើយបន្ទាប់មកសង្ខេបដោយគូសជាគំនូសបំព្រួញនៃដំណើរការអនុម័ត ។ មុននឹងឈានទៅដល់ ការពន្យល់បកស្រាយខ្លឹមសារមេរៀន អ្នកសំរបសំរួល ត្រូវបញ្ជាក់ជាមួយសិក្ខាកាមថា "សមាជិក គ.ជ.ថ របស់ឃុំ សង្កាត់ទាំងអស់ បានអានសេចក្តីព្រាងកម្មវិធីវិនិយោគនេះ" ។ ក្នុងករណី ឃុំ សង្កាត់ មិនមានធនធានគ្រប់គ្រាន់ ដើម្បីថតចំលងឯកសារទាំងនេះសំរាប់សមាជិក គ.ជ.ថ ទាំងអស់ទេ មេឃុំ ចៅសង្កាត់ ត្រូវរៀបចំការបង្ហាញមួយយ៉ាងលំអិត និងច្បាស់លាស់ ដល់ពួកគេ ។

២. អ្នកសំរបសំរួល ពន្យល់ខ្លឹមសារមេរៀន (ផ្អែកតាមសេចក្តីណែនាំបច្ចេកទេស) :

- ការផ្ញើសេចក្តីព្រាងកម្មវិធីវិនិយោគទៅអភិបាលខេត្ត ក្រុង ។ តើហេតុអ្វីចាំបាច់ផ្ញើសេចក្តីព្រាងនេះទៅអភិបាលខេត្ត ក្រុង?
- ការបង្ហាញសេចក្តីព្រាងកម្មវិធីវិនិយោគដល់អ្នកភូមិទាំងអស់ ។ តើហេតុអ្វីចាំបាច់បង្ហាញសេចក្តីព្រាងនេះទៅអ្នកភូមិ?
- ការពិនិត្យ និងសរុបនូវរាល់មតិយោបល់ទាំងអស់ ដើម្បីកែតំរូវកម្មវិធីវិនិយោគ ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យអនុម័តកម្មវិធីវិនិយោគឃុំ សង្កាត់ ។